ដាប់ប៊ែលយូប៊ី ហ្វាយនែន
WB FINANCE

របាយការណ៍ប្រចាំឆ្នាំ

2019

គ្រឹះស្ថានហិរញ្ញវត្ថុ
ដែលកាន់តែរឹងមាំ

សមាជិកគ្រួសាររបស់ **ធនាគារអ៊ូរី ប្រទេសកូរ៉េ**

ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក

សមាជិកគ្រួសាររបស់ធនាគារ អ៊ូរី

“ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន ជាគ្រឹះស្ថានទទួល បានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើ ពីធនាគារជាតិ នៃកម្ពុជា និង ជាសមាជិកគ្រួសាររបស់ធនាគារ អ៊ូរី ដែលជាធនាគារពាណិជ្ជឈានមុខគេនៅប្រទេសកូរ៉េ។ ដាប់ប៊ែលយូប៊ី ហ្វាយនែន បានបម្រើសេវាហិរញ្ញវត្ថុដល់ប្រជាជនកម្ពុជា ជាង 20 ឆ្នាំ មកហើយ ជាមួយនឹងការផ្តល់ជូនផលិតផល និងសេវាហិរញ្ញវត្ថុដ៏សម្បូរបែប តាមរយៈបុគ្គលិកជំនាញដែលកំពុងបម្រើការនៅតាមបណ្តាញសាខាគ្រប់ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា។ ”

របាយការណ៍ប្រចាំឆ្នាំ 2019

មាតិកា

អំពីស្ថាប័ន	4
ដាប់ប៊ែលយូប៊ី ហ្វាយនែន ជានរណា? ទស្សនវិស័យ បេសកកម្ម	7
ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ	8
អំពីធនាគារ អ៊ូរី	10
សារពីប្រធានក្រុមប្រឹក្សាភិបាល	12
សារពីអគ្គនាយកប្រតិបត្តិ	14
រចនាសម្ព័ន្ធក្រុមហ៊ុន	16
អំពីក្រុមប្រឹក្សាភិបាល	18
អំពីគណៈគ្រប់គ្រងជាន់ខ្ពស់	22
ចំណុចសំខាន់ៗអំពីអាជីវកម្ម	28
ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ	30
ការអភិវឌ្ឍធនធានមនុស្ស	36
ព័ត៌មានសំខាន់ៗ	38
អំពីភាពជោគជ័យរបស់អតិថិជន	44
ផលិតផល និងសេវាកម្មរបស់យើង	48
របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម	62
បណ្តាញសាខា និង តំបន់ប្រតិបត្តិការ	64
របាយការណ៍ហិរញ្ញវត្ថុ	66
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ	68
របាយការណ៍លទ្ធផលលម្អិត	70
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន	71
របាយការណ៍លំហូរទឹកប្រាក់	72
របាយការណ៍របស់សវនករឯករាជ្យ	74
បណ្តាញអន្តរជាតិរបស់ ធនាគារ អ៊ូរី	80

អំពីស្ថាប័ន

NCE
우리은행

WB FINANCE
We Believe
WB FINANCE
WB FINANCE

អំពីស្ថាប័ន

ដាប់ប៊ែលយូប៊ី ហ្វាយនែន ជានរណា ?

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន ជាគ្រឹះស្ថានទទួលបានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើ ធំជាងគេមួយនៅកម្ពុជាដែលបាននឹងកំពុងបម្រើសេវា និងផលិតផលហិរញ្ញវត្ថុ ដល់ប្រជាជនកម្ពុជា អស់រយៈពេលជាង **20** ឆ្នាំ មកហើយនៅទូទាំងប្រទេស ។ ដាប់ប៊ែលយូប៊ី ហ្វាយនែន បានប្តេជ្ញាធ្វើឱ្យជីវិតកាន់តែប្រសើរឡើងតាមរយៈដំណោះស្រាយហិរញ្ញវត្ថុដ៏ឆ្លាតវៃនិងសាមញ្ញដោយរួមបញ្ចូលបច្ចេកវិទ្យាទំនើបនិង ផលិតផលនិងសេវាហិរញ្ញវត្ថុថ្មីៗដែលសាកសមបំផុតទៅនឹងតម្រូវការរបស់អតិថិជន។ គិតត្រឹម ខែមីនា ឆ្នាំ **2020** ដាប់ប៊ែលយូប៊ី ហ្វាយនែន បានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនដល់ **136** សាខាទូទាំងប្រទេស។ ដាប់ប៊ែលយូប៊ី ហ្វាយនែន ជាសមាជិកគ្រួសាររបស់ធនាគារពាណិជ្ជ អ៊ូរី ដែលជាធនាគារឈានមុខគេមួយនៅប្រទេសកូរ៉េ ត្រូវបានបង្កើតឡើងនៅឆ្នាំ**1899**។

យើងកំពុងតែជម្រុញឱ្យមានកំណើនលូតលាស់ ជួយបង្កើតការងារដល់សហគមន៍ ដើម្បីជម្រុញការ បំលាស់ប្តូរសេដ្ឋកិច្ច និងដោះស្រាយបញ្ហាប្រឈមធំៗ នៅក្នុងសង្គម ខណៈដែលយើងអាចគ្រប់គ្រងហានិភ័យបានទាំងស្រុង ជាមួយនឹងការផ្តល់ត្រឡប់ទៅ អតិថិជន និងភាគទុនិករបស់យើងវិញនូវភាពរីកចម្រើន។ ដោយសារតែយើងទទួលស្គាល់ថា យើងអាចទទួលបានជោគជ័យនៅពេលដែល អតិថិជន បុគ្គលក្រុមហ៊ុនសហគមន៍ និងបុគ្គលិកដែលយើងបម្រើអាចឈានដល់ទស្សនវិស័យជោគជ័យរបស់ពួកគេ។

ទស្សនវិស័យ

ទស្សនវិស័យរបស់យើង ចង់ឃើញប្រជាជនកម្ពុជាគ្រប់រូបមានជីវិតពេញបរិបូរណ៍។

បេសកកម្ម

ក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខគេដែលផ្តល់នូវសក្តានុពលសេដ្ឋកិច្ចដើម្បីឲ្យកម្ពុជារីកចម្រើន។

ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

1990s

ត្រូវបានបង្កើតឡើងជាសកម្មភាពមួយរបស់កម្មវិធីអភិវឌ្ឍន៍តំបន់ របស់អង្គការទស្សនៈពិភពលោកកម្ពុជា។

2000

ត្រូវបានដាក់ឈ្មោះថា កម្មវិធីអភិវឌ្ឍន៍សហគ្រាសខ្នាតតូច ដែលជាកម្មវិធីឥណទានមួយរបស់អង្គការទស្សនៈពិភពលោកកម្ពុជា។

2003

បានក្លាយជាក្រុមហ៊ុនមួយបានចុះបញ្ជីដោយមានឈ្មោះថា វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី នៅក្រសួងពាណិជ្ជកម្ម។

2004

ទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដោយមានឈ្មោះថា វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី។

2011

ទទួលបានអាជ្ញាបណ្ណប្រមូលប្រាក់បញ្ញើ ពី ធនាគារជាតិនៃកម្ពុជា។

2016

- ការសម្ពោធជាផ្លូវការ អគារការិយាល័យកណ្តាលថ្មី
- ទទួលបានការទទួលស្គាល់ថា ស្ថាប័នបានគោរពតាមគោលការ ការពារអតិថិជន យ៉ាងខ្ជាប់ខ្ជួន និងត្រូវតាមស្តង់ដារអន្តរជាតិពី Smart Campaign

2017

- ទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ ប្រភេទមាស ពីអគ្គនាយកដ្ឋានពន្ធដារ នៃព្រះរាជាណាចក្រកម្ពុជា។
- ជាសមាជិកស្ថាបនិកនៃគម្រោង NBC FAST ហើយបានបញ្ចប់ការធ្វើសមាហរណកម្មយ៉ាងពេញលេញ។



2018

ផ្លាស់ប្តូរម្ចាស់ភាគហ៊ុន (មិថុនា 2018) ទៅជាធនាគារអ៊ូរី នៃប្រទេសកូរ៉េ ខាងត្បូង

2019

- គិតត្រឹមខែធ្នូឆ្នាំ 2019 អតិថិជនប្រាក់កម្ចី មានចំនួន 133.284
- សំពៀតឥណទានចំនួន USD 335.5 លានដុល្លារអាមេរិក
- សមតុល្យប្រាក់បញ្ញើសន្សំចំនួន USD 66.3 លានដុល្លារអាមេរិក
- បានទទួលការអនុម័តជាគោលការណ៍ពីធនាគារជាតិនៃកម្ពុជាលើសំណើសុំគួបបញ្ចូលគ្នាជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី។

អំពីធនាគារ អ៊ូរី

គិតត្រឹមត្រីមាសទី 3 ឆ្នាំ 2019

ធនាគារ អ៊ូរី គឺជាម្ចាស់ភាគហ៊ុនតែមួយគត់របស់ ដាប់ប៊ែលយូប៊ី ហ្វាយនែន ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុង សេអ៊ូល ប្រទេសកូរ៉េខាងត្បូង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ**1899** ជាធនាគារពាណិជ្ជឈានមុខគេមួយ នៅប្រទេសកូរ៉េ ដែលមានបណ្តាញអន្តរជាតិដ៏ធំទូលាយ នៅទូទាំងពិភពលោក ផ្តល់ជូននូវការវិនិយោគលើវិស័យពាណិជ្ជកម្ម និង វិស័យធនាគារយ៉ាងទូលំទូលាយ តាមរយៈបណ្តាញប្រតិបត្តិការនៅក្នុងស្រុកចំនួន **747** សាខា និងក្រៅស្រុកចំនួន **451** សាខា នៅក្នុង **26** ប្រទេស។ ក្នុងឆ្នាំ 2019 នេះធនាគារ អ៊ូរី អបអរសាទរខួបទី **120** ដែលខ្លួនបានរក្សា ប្រវត្តិសាស្រ្តរបស់ខ្លួននៅលើទីផ្សារហិរញ្ញវត្ថុអស់រយៈពេលជាងមួយសតវត្សរ៍មកហើយ។

គិតត្រឹមត្រីមាសទី **3** ឆ្នាំ **2019** ធនាគារ អ៊ូរី មានទ្រព្យសកម្មសរុបចំនួន **286** ពាន់លានដុល្លារអាមេរិក ផលប័ត្រឥណទានសរុប **185** ពាន់លានដុល្លារអាមេរិក ប្រាក់ចំណេញប្រតិបត្តិការ **3.9** ពាន់លានដុល្លារអាមេរិក និងប្រាក់ចំណេញ **1.0** ពាន់លានដុល្លារអាមេរិក ដែលត្រូវបានបង្ហាញ។

បណ្តាញសាខាអន្តរជាតិនៅជុំវិញពិភពលោក

747

សាខាក្នុងស្រុក

451

សាខាក្រៅស្រុក

មានទ្រព្យសកម្មសរុបចំនួន

US$286

ពាន់លានដុល្លារអាមេរិក

ផលប័ត្រឥណទានសរុប

US$185

ពាន់លានដុល្លារអាមេរិក

ប្រាក់ចំណេញប្រតិបត្តិការ

US$3.9

ពាន់លានដុល្លារអាមេរិក

ប្រាក់ចំណេញ

US$1.0

ពាន់លានដុល្លារអាមេរិក

“ ធនាគារ អ៊ូរី ដែលបានក្លាយជាម្ចាស់ភាគហ៊ុនតែមួយរបស់ ដាប់ប៊ែលយូប៊ី ហ្វាយនែន តាំងពីពាក់កណ្ដាលឆ្នាំ **2018** បានរក្សាកំណើនរឹងមាំ របស់ខ្លួន និងរួមចំណែកនៅក្នុងទីផ្សារហិរញ្ញវត្ថុកម្ពុជា។ ”

សារពី ប្រធាន ក្រុមប្រឹក្សាភិបាល

“ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាភិបាលថ្មីនៃគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ខ្ញុំពិតជាមានក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានឃើញពីភាពរីកចម្រើនយ៉ាងឆាប់រហ័សរបស់គ្រឹះស្ថាន។”

រយៈពេល1ឆ្នាំកន្លះនៃការផ្លាស់ប្តូរម្ចាស់ភាគហ៊ុន និងក្រោមការគ្រប់គ្រប់របស់ធនាគារ អ៊ូរី បង្ហាញឲ្យឃើញពីការវិវត្ត ក៏ដូចជាការបន្តការរីកចម្រើនខ្លាំងជាងមុននៃគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន និងបានបង្ហាញឲ្យឃើញពីមហិច្ឆតារបស់ខ្លួនក្នុងការរីកចម្រើននៅក្នុងវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។

ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាភិបាលថ្មីនៃគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ខ្ញុំពិតជាមានក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានឃើញពីភាពរីកចម្រើនយ៉ាងឆាប់រហ័សរបស់គ្រឹះស្ថាន។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក គ្រិស្ត៍ ប្រាយអាន ដែលជាអតីតប្រធានក្រុមប្រឹក្សាភិបាលនាអាណត្តិកន្លងមក ដែលបានដឹកនាំគ្រឹះស្ថានប្រកបដោយភាពរីកចម្រើន និងការផ្លាស់ប្តូរជាវិជ្ជមានក្រោមម្ចាស់ភាគហ៊ុនថ្មី ធនាគារ អ៊ូរី នៃប្រទេសកូរ៉េខាងត្បូង។

ជាលទ្ធផលក្នុងឆ្នាំ**2019** គ្រឹះស្ថានសម្រេចបាននូវលទ្ធផលឥណទានក្នុងអត្រាកំណើនប្រមាណ **54%** ជាមួយនឹងប្រាក់ចំណេញជាង **12.8** លានដុល្លារអាមេរិក ហើយអនុបាតឥណទានមិនដំណើរការធ្លាក់ចុះពី **0.64%** នៅឆ្នាំ **2018** មកត្រឹម **0.30%** នៅឆ្នាំ **2019** ដែលបង្ហាញឲ្យឃើញពីការគ្រប់គ្រងគុណភាពឥណទានដ៏ល្អ។ ក្នុងនោះផងដែរ ប្រាក់បញ្ញើសន្សំសរុបរបស់គ្រឹះស្ថានបានកើនឡើងដល់ **66.3** លានដុល្លារអាមេរិក។ តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ និងហិរញ្ញប្បទានភេរវកម្ម កំណើនប្រាក់សន្សំរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន បានឡើងដល់ **7.4%**។ ទោះជាយ៉ាងនេះក្តី គ្រឹះស្ថានបាននឹងកំពុងខិតខំបន្ថែមទៀត ដើម្បីបង្កើនផលប័ត្រប្រាក់បញ្ញើតាមរយៈការបង្កើនទំនុកចិត្តដល់សាធារណជនគ្រប់ស្រទាប់វណ្ណៈ ជាមួយនឹងការអភិវឌ្ឍលក្ខខណ្ឌផលិតផលនិងសេវាកម្ម ការធ្វើទំនើបកម្មប្រព័ន្ធធនាគារចល័ត និងប្រព័ន្ធធនាគារស្នូល រួមទាំងប្រព័ន្ធបច្ចេកវិទ្យាផ្សេងៗផងដែរ។

ជាការពិតណាស់លទ្ធផលដែលសម្រេចបាននេះ មិនអាចកើតឡើងបានទេប្រសិនបើគ្មានការចូលរួមខិតខំប្រឹងប្រែងពីសំណាក់បុគ្គលិក គណៈគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ជាពិសេសអតិថិជន និងដៃគូទាំងអស់។ ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណយ៉ាងក្រៃលែងដល់ អតិថិជន បុគ្គលិក គណៈគ្រប់គ្រង ក៏ដូចជាដៃគូទាំងអស់ ជាពិសេសអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ដែលបានចូលរួមខិតខំប្រឹងប្រែង គាំទ្រនូវគ្រប់ប្រតិបត្តិការទាំងអស់របស់គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន រហូតឈានដល់ចំណុចនេះ។ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថាន សូមប្តេជ្ញាក្នុងការដឹកនាំ និងគាំទ្រនូវគ្រប់ប្រតិបត្តិការរបស់គ្រឹះស្ថានបន្តទៀតប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីប្រែក្លាយឲ្យទៅជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជានាពេលខាងមុខដ៏ខ្លី។

សូមអរគុណ

យូន ហ៊ា្យន់ សង់

ប្រធានក្រុមប្រឹក្សាភិបាល

សារពី អគ្គនាយកប្រតិបត្តិ

“ក្នុងនាមជាអគ្គនាយកគ្រឹះស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅ និងសូមសំដែងការកោតសរសើរដល់ អតិថិជន ដៃគូ បុគ្គលិកថ្នាក់គ្រប់គ្រង ម្ចាស់ភាគទុនិក និងភាគីពាក់ព័ន្ធ ដទៃទៀតជាពិសេសធនាគារជាតិនៃ កម្ពុជា”

ជាមួយនឹងការធ្លាក់ចុះដោយចៀសមិនរួចនៃការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម នយោបាយ និងការអភិវឌ្ឍបច្ចេកវិទ្យា ក៏ដូចជាភាពតានតឹងនៃពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ចពិភពលោក បានធ្វើឲ្យកំណើនសេដ្ឋកិច្ចពិភពលោកបានថយចុះមកត្រឹមប្រមាណ **3%** នៅក្នុងឆ្នាំ **2019**។ បើទោះបីជាដូច្នោះក៏ដោយកម្ពុជាមិនបានទទួលរងនូវឥទ្ធិពលដោយផ្ទាល់នៃភាពយឺតយ៉ាវនៃកំណើនសេដ្ឋកិច្ចពិភពលោកនោះទេ ហើយនៅតែរក្សាបានជាប្រទេសមួយដែលបាននឹងកំពុងមានភាពរីកចម្រើន និងអភិវឌ្ឍន៍យ៉ាងលឿនជាងគេមួយក្នុងចំណោមបណ្តាប្រទេសជាច្រើន

នៅក្នុងតំបន់ និងក្នុងពិភពលោក និងបន្តមានកំណើនយ៉ាងរឹងមាំនៃវិស័យកម្មន្តសាល សំណង់ និងទេសចរណ៍។ ប្រទេសកម្ពុជារក្សាបាននូវអត្រាកំណើនសេដ្ឋកិច្ចរបស់ខ្លួនជាមធ្យមក្នុងរង្វង់ប្រមាណ **8%** នៅចន្លោះឆ្នាំ **1994** និងឆ្នាំ **2018** ដែលធ្វើឲ្យប្រទេសនេះក្លាយជាប្រទេសមួយដែលមានអត្រាកំណើនសេដ្ឋកិច្ចលឿនបំផុតនៅក្នុងពិភពលោក ខណៈពេលដែលអត្រាកំណើននេះនៅតែរក្សាបាននៅរង្វង់ **7.1%** នៅក្នុងឆ្នាំ **2019** បើប្រៀបធៀបនឹងអត្រាកំណើន **7.5%** នៅក្នុងឆ្នាំ **2018** (របាយការណ៍ធនាគារពិភពលោក)។

ទន្ទឹមនឹងនោះ វិស័យហិរញ្ញវត្ថុ ជាពិសេសវិស័យធនាគារបាននឹងកំពុងមានភាពរីចម្រើនយ៉ាងខ្លាំងនៅរយៈពេលចុងក្រោយនេះ ហើយវិស័យនេះបានចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិផងដែរ។ គិតត្រឹមចុងឆ្នាំ **2019** ចំនួនគ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណមានចំនួន**143** (ធនាគារពាណិជ្ជ **46** ធនាគារឯកទេស **15** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ **7** គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **75**) ដោយទ្រព្យសកម្មនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើង **24.5%** ហើយឥណទានបានកើន **26%** កំណើនចំនួនគណនីប្រាក់បញ្ញើកើនរហូតដល់ **7.5** លានគណនី និង **3.1** គណនីឥណទាន ជាមួយនឹងអនុបាតឥណទានមិនដំណើរការស្ថិតក្នុងកម្រិតទាបត្រឹម **2.2%** នៃគ្រឹះស្ថានធនាគារ និង**1.1%** សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ **2019** របស់ធនាគារជាតិនៃកម្ពុជា។

ដោយឡែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែនបានវិវត្តខ្លួន យ៉ាងឆាប់រហ័សមួយកម្រិតទៀតនៅពេលដែលធនាគារ អ៊ូរី បានក្លាយជាម្ចាស់ភាគហ៊ុនរបស់ខ្លួន។ ជាលទ្ធផលគ្រឹះស្ថានសម្រេចបាននូវលទ្ធផលជាផ្លែផ្កានូវចំនួនសមតុល្យរបស់ខ្លួននៅឆ្នាំ **2019** សរុបរហូតដល់ **335.5** លានដុល្លារអាមេរិកកើនឡើងប្រមាណ **54%** បើធៀបនឹងឆ្នាំ **2018** ហើយស្ថិតក្នុងចំណាត់ថ្នាក់លេខ **2** ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលមានកំណើនសមតុល្យឥណទានច្រើននៅក្នុងឆ្នាំ **2019** ខណៈដែលប្រាក់ចំណេញរបស់ខ្លួនកើនឡើងរហូតដល់ **12.8** លានដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ **2018** ប្រមាណ **4** លានដុល្លារអាមេរិកជាមួយនឹងឥណទានមិនដំណើរការធ្លាក់ចុះពី **0.64%** មក **0.30%**ដែលបង្ហាញពីអត្រាកំណើនមួយដែលប្រកបដោយសុខភាពល្អបំផុតមួយនៅក្នុងវិស័យហិរញ្ញវត្ថុ។ លើសពីនេះ គ្រឹះស្ថានសម្រេចបាននូវបញ្ញត្តិដែលដាក់ចេញដោយធនាគារជាតិនៃកម្ពុជា អំពីសមតុល្យឥណទានជាប្រាក់រៀលចំនួន **18.32%** នៃសមតុល្យឥណទានសរុប។ បន្ថែមពីនេះ គ្រឹះស្ថានបាននឹងកំពុងឈានទៅមុខក្នុងការធ្វើទំនើបកម្មនៃប្រព័ន្ធធនាគារស្នូលរបស់ខ្លួន ហើយបាននឹងកំពុងអភិវឌ្ឍផលិតផលសេវាកម្មរបស់ខ្លួនឲ្យកាន់តែមានលក្ខខណ្ឌល្អប្រសើរបន្ថែមទៀត។

ក្នុងនាមជាអគ្គនាយកគ្រឹះស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមសំដែងការកោតសរសើរដល់អតិថិជន ដៃគូបុគ្គលិក គណៈគ្រប់គ្រង ម្ចាស់ភាគហ៊ុន និងភាគីពាក់ព័ន្ធដទៃទៀតជាពិសេសធនាគារជាតិនៃកម្ពុជា ដែលតែងតែជួយជ្រោមជ្រែងនិងផ្តល់អនុសាសន៍ដ៏ល្អៗ ក៏ដូចជាការសហការដ៏ល្អកន្លងជាមួយគ្រឹះស្ថាន ក្នុងការបង្កើតនូវលទ្ធផលការងារដ៏មានផ្លែផ្កានេះ និងគាំទ្រប្រតិបត្តិការរបស់គ្រឹះស្ថានទាំងមូល។ យើងខ្ញុំនឹងខិតខំបន្តផ្តល់នូវផលិតផល និងសេវាហិរញ្ញវត្ថុដ៏ល្អបំផុតដល់អតិថិជន ដៃគូនិងសាធារណជនទាំងអស់នៅឆ្នាំបន្តបន្ទាប់ទៀត។

សូមអរគុណ

គីម ស៊ុនឃ្យូ
អគ្គនាយកប្រតិបត្តិ

រចនាសម្ព័ន្ធក្រុមហ៊ុន

គិតត្រឹម ខែមិថុនា ឆ្នាំ 2019





ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការកម្រិតក្រុមប្រឹក្សាភិបាលសវនកម្មផ្ទៃក្នុង
អគ្គនាយកប្រតិបត្តិ
ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
ប្រធានសវនកម្មផ្ទៃក្នុង
ប្រធានសវនកម្មផ្ទៃក្នុង
ប្រធានសវនកម្មផ្ទៃក្នុង
ប្រធានសវនកម្មផ្ទៃក្នុង
ប្រធានសវនកម្មផ្ទៃក្នុង
អគ្គនាយកហិរញ្ញវត្ថុ
នាយកនៃអគ្គនាយកដ្ឋាន ហិរញ្ញវត្ថុ
ប្រធាននាយកដ្ឋានវិភាគឥណទាន
ប្រធានលេខាធិការដ្ឋាន និងកិច្ចការច្បាប់
នាយកហិរញ្ញវត្ថុ
ប្រធាននាយកដ្ឋានគ្រប់គ្រងគម្រោង
នាយកព័ត៌មានវិទ្យា
នាយកធនធានមនុស្ស
ប្រធានផ្នែកវិភាគឥណទាន
ប្រធានផ្នែកវិភាគឥណទាន
ប្រធានផ្នែកវិភាគឥណទាន
ប្រធានផ្នែកវិភាគឥណទាន
ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ
ប្រធាននាយកដ្ឋានរដ្ឋបាល
ប្រធានផ្នែកផែនការ និងវិភាគហិរញ្ញវត្ថុ
ប្រធានផ្នែកជំនួយរតនាគារ
ប្រធានផ្នែកប្រតិបត្តិការសាច់ប្រាក់
ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ប្រព័ន្ធធនាគារ និងព័ត៌មាន
ប្រធាននាយកដ្ឋានបណ្ដាញកុំព្យូទ័រ
ប្រធានផ្នែកប្រព័ន្ធគាំទ្រអាជីវកម្ម និងពង្រឹងគុណភាព
ប្រធានផ្នែកប្រព័ន្ធសុវត្ថិភាពព័ត៌វិទ្យា
ប្រធានផ្នែកជ្រើសរើសបុគ្គលិក និង សេវាធនធានមនុស្ស

អំពីក្រុម
ប្រឹក្សាភិបាល

អំពីក្រុមប្រឹក្សាភិបាល

លោក យូន ហ៊្យន់ សង់
ប្រធានក្រុមប្រឹក្សាភិបាល
ត្រូវបានតែងតាំងនៅថ្ងៃទី **10** ខែកុម្ភៈ ឆ្នាំ**2020**

លោក យូន ហ៊្យន់ សង់ ទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៅសាកលវិទ្យាល័យជាតិ សេអ៊ូល។ គាត់បច្ចុប្បន្នជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករសាធារណៈរបស់ប្រទេសកូរ៉េ(KICPA)។

លោកបានចូលបម្រើការងារនៅធនាគារ អ៊ូរី ក្នុងខែឧសភា ឆ្នាំ2012។ មុនពេលចូលរួមជាមួយធនាគារ អ៊ូរី លោកបានបម្រើការងារឲ្យក្រុមហ៊ុនគណនេយ្យធំៗ តាំងពីឆ្នាំ2000មក។ អាជីពរបស់គាត់បានចាប់ផ្តើមជាមួយ PwC ដែលជាក្រុមហ៊ុនគណនេយ្យពិភពលោក។ ពេលកំពុងបម្រើការងារនៅក្រុមហ៊ុនគណនេយ្យ លោកមានបទពិសោធន៍លើមុខជំនាញផ្សេងៗដូចជាសវនកម្ម ប្រឹក្សាយោបល់ ប្រឹក្សាយោបល់លើប្រតិបត្តិការក្រុមហ៊ុន ជាមួយនឹងក្រុមហ៊ុនសវនកម្ម E&Y។ បទពិសោធន៍ទាំងនោះបានជួយលោកឲ្យមានទស្សនៈប្រកបដោយតុល្យភាពពីគ្រប់ផ្នែក ក្នុងការកំណត់បញ្ហាសក្តានុពល វិភាគមូលហេតុ និងផលប៉ះពាល់។ លោកកំពុងបម្រើការងារជា នាយករងគ្រប់គ្រងទូទៅ នៅក្នុងនាយកដ្ឋានយុទ្ធសាស្រ្តធុរកិច្ចសកល នៅធនាគារ អ៊ូរី។

បច្ចុប្បន្ន លោក យូន ក៏មានតួនាទីជាប្រធានក្រុមប្រឹក្សាភិបាល ក្រោយពីទទួលបានការអនុម័តយល់ព្រមជាផ្លូវការនៃការច្របាច់បញ្ចូលគ្នារវាងគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក និងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី ពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្មក្នុងដើមឆ្នាំឆ្នាំ2020។

លោកស្រី ហ្វីអូណា វ៉ាយត៍
សមាជិកក្រុមប្រឹក្សាភិបាល

លោកស្រី ហ្វីអូណា វ៉ាយត៍ មានសញ្ជាតិនូវែលសេឡង់។ លោកស្រីមានតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន (រួមទាំងជាអតីតវីសិនហ្វាន់ (ខេមបូឌា)) ចាប់តាំងពីខែមករា ឆ្នាំ2013។ លោកស្រីមានបទពិសោធន៍ 7ឆ្នាំខាងផ្នែកបទប្បញ្ញត្តិ បន្ថែមលើបទពិសោធន៍ផ្នែកធនាគាររយៈពេល23ឆ្នាំ ដែលក្នុងនោះ12 ឆ្នាំ ក្នុងការងារគ្រប់គ្រងហានិភ័យនៃការប្តូររូបិយប័ណ្ណអន្តរជាតិនៅប្រទេសនូវែលសេឡង់។

លោកស្រីបានបញ្ចប់ការសិក្សាផ្នែក គ្រប់គ្រងអាជីវកម្មអន្តរជាតិនៅសាកលវិទ្យាល័យ Massey ក្នុងឆ្នាំ2007។ បច្ចុប្បន្ន លោកស្រី ហ្វីអូណា វ៉ាយត៍ កំពុងបម្រើការងារជាមួយអាជ្ញាធរទីផ្សារហិរញ្ញវត្ថុ ក្នុងប្រទេសនូវែលសេឡង់។ កាលពីមុន លោកស្រីក៏បានបម្រើការងារជាក្រុមប្រឹក្សាភិបាលជាមួយអង្គការទស្សនៈពិភពលោកនៅប្រទេសនូវែលសេឡង់ផងដែរ។ បច្ចុប្បន្នលោកស្រីមានតួនាទីជាប្រធានគណៈកម្មាធិការ សវនកម្ម និងប្រធានគណៈកម្មាធិការអភិបាលកិច្ច និងតម្លៃការ របស់គ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន ផងដែរ។

លោក គីម សុន យ្យ
សមាជិកក្រុមប្រឹក្សាភិបាល

លោក គីម សុន យ្យ បានចូលរួមនឹងដាប់ប៊ែលយូប៊ី ហ្វាយនែនជា អគ្គនាយកប្រតិបត្តិនៅក្នុងខែកុម្ភៈឆ្នាំ 2019។ លោកមានបទពិសោធន៍ជាច្រើនក្នុងផ្នែកធនាគារពាណិជ្ជកម្មនៅធនាគារ អ៊ូរី ក្នុងប្រទេសកូរ៉េ។ ចាប់តាំងពីលោកចូលរួមជាមួយធនាគារ អ៊ូរី នៅឆ្នាំ 1979 លោកបានទទួលចំណេះដឹង និងបទពិសោធន៍យ៉ាងទូលំទូលាយផ្នែកសេវាហិរញ្ញវត្ថុ។ លោកបានទទួលបន្ទុកផ្នែកប្រតិបត្តិការនៅតាមសាខាមួយចំនួនដែលផ្តោតលើការលក់ផលិតផលឥណទាន។ លោកក៏បានទទួលបន្ទុកផ្នែកកម្ចីឯកជន និងកម្ចីសាជីវកម្ម ព្រមទាំងបម្រើការងារជា Corporate Loan Underwriter អស់រយៈពេល 8ឆ្នាំ។ បន្ទាប់មក លោកបានបម្រើការងារជាអ្នកគ្រប់គ្រងទូទៅនៅតាមបណ្តាសាខាជាច្រើនអស់រយៈពេល 5 ឆ្នាំ, លោកត្រូវបានតំឡើងតំណែងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ដែលទទួលខុសត្រូវលើការគ្រប់គ្រងកម្ចីឯកជន និងកម្ចីសាជីវកម្មរយៈពេល 2 ឆ្នាំ។

មុនចូលបម្រើការងារនៅ ដាប់ប៊ែលយូប៊ី ហ្វាយនែន លោកបានបម្រើការងារនៅធនាគារ អ៊ូរី ទីក្រុង សេអ៊ូល ជាអគ្គនាយករងប្រតិបត្តិ។ លោកក៏ធ្លាប់បម្រើការងារជានាយកគ្រប់គ្រងនៃផ្នែកកំណែទម្រង់អាជីវកម្មផងដែរ។

នៅខែធ្នូ ឆ្នាំ 2015 លោកបានទទួលតំណែងថ្មីជានាយកប្រតិបត្តិកំណែទម្រង់អាជីវកម្ម ព្រមទាំងបានធ្វើកំណែទម្រង់មួយចំនួន និងសេចក្តីសម្រេច M&A សម្រាប់ក្រុមហ៊ុនធំៗជាច្រើន។ ចាប់ពីឆ្នាំ 2016 ដល់ខែធ្នូ ឆ្នាំ2018 លោកបានទទួលតំណែងជាអគ្គនាយករងផ្នែកឥណទាន។

លោកបានទទួលបរិញ្ញាបត្រពាណិជ្ជកម្មដែលចេញពី សកលវិទ្យាល័យ Sejong។ ហើយលោកក៏បានទទួលវិញ្ញាបនបត្រសមត្ថភាពបញ្ជាក់ពី Fund Investment Advisor ជាបុគ្គលិកឥណទាន និង អ្នកវិភាគឥណទាន។

លោក គីម ឆាងយ៉ុន
សមាជិកក្រុមប្រឹក្សាភិបាល

លោក គីម ឆាងយ៉ុន បានចូលបម្រើការងារនៅ ដាប់ប៊ែលយូប៊ី ហ្វាយនែន នៅក្នុងខែ មិថុនា ឆ្នាំ 2018 ជាមួយនឹងបទពិសោធន៍ដ៏ទូលំទូលាយជាង 32 ឆ្នាំ លើផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ និងប្រតិបត្តិការ សេវាធនាគារពាណិជ្ជកម្ម វិនិយោគទុន រតនាគារ និងសេវាពាណិជ្ជកម្មអន្តរជាតិ។

មុនចូលបម្រើការងារនៅ ដាប់ប៊ែលយូប៊ី ហ្វាយនែន លោកធ្លាប់បានបម្រើការងារជាមួយធនាគារ អ៊ូរី ទីក្រុងសេអ៊ូល ក្នុងមុខតំណែងជាប្រធានមជ្ឈមណ្ឌលសេវាពាណិជ្ជកម្មអន្តរជាតិ។ លោកក៏បានបម្រើការងារជាប្រធានគ្រប់គ្រងទូទៅនៃនាយកដ្ឋានរតនាគារផងដែរ។

លោកមានបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មពីសកលវិទ្យាល័យ Sogang ក្នុងទីក្រុងសេអ៊ូល។ លោកក៏ទទួលបានងារជាអ្នកវិភាគហិរញ្ញវត្ថុពី វិទ្យាស្ថាន C.F.A នៅក្នុងឆ្នាំ2005 ផងដែរ។

លោក គី ប៊ុនទ្រាន
សមាជិកក្រុមប្រឹក្សាភិបាល
ត្រូវបានតែងតាំងនៅថ្ងៃទី 10 ខែកុម្ភៈ ឆ្នាំ2020

លោក គី ប៊ុនទ្រាន បានចូលរួមជាមួយដាប់ប៊ែលយូប៊ី ហ្វាយនែន ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ លោកទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រនិងវិទ្យាសាស្ត្រនយោបាយ ព្រមទាំងសញ្ញាបត្រពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មុននេះ លោកជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា ចាប់ពីឆ្នាំ 2018 រហូតដល់ដើមឆ្នាំ 2020។ ក្រៅពីនេះ លោកក៏ជាសមាជិកមួយរូបនៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា និងជាសាស្ត្រាចារ្យបង្រៀនក្រៅម៉ោងនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផងដែរ។

បន្ទាប់ពីការច្របាច់បញ្ចូលគ្នាដោយជោគជ័យរវាងគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន និងគ្រឹះស្ថាន អ៊ូរី ហ្វាយនែន ខេមបូឌា លោក គី ប៊ុនទ្រាន ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៃគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន។

សូមអរគុណ
អតីតសមាជិកក្រុមប្រឹក្សាភិបាលរបស់យើង ដែលបានបញ្ចប់អាណត្តិ របស់ខ្លួន

លោកលោក គ្រិស ប្រាយអាន,
ប្រធានក្រុមប្រឹក្សាភិបាល
(បញ្ចប់អាណត្តិនៅថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ 2020)

លោក ចូ ប៊ែក ហ៊ី យ៉ុន
សមាជិកក្រុមប្រឹក្សាភិបាល
(បញ្ចប់អាណត្តិថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ 2020)

អំពីគណៈគ្រប់គ្រងជាន់ខ្ពស់

អំពីគណៈគ្រប់គ្រងជាន់ខ្ពស់

លោក គីម សុន យ្យូ
អគ្គនាយកប្រតិបត្តិ

លោក គីម សុន យ្យូ បានចូលរួមនឹងដាប់ប៊ែលយូប៊ី ហ្វាយនែន ជា អគ្គនាយកប្រតិបត្តិ នៅក្នុងខែកុម្ភៈឆ្នាំ 2019។ លោកមានបទពិសោធន៍ជាច្រើនក្នុងផ្នែកធនាគារពាណិជ្ជកម្ម នៅធនាគារ អ៊ូរី ក្នុងប្រទេសកូរ៉េ។ ចាប់តាំងពីលោកចូលរួមជាមួយធនាគារ អ៊ូរី នៅឆ្នាំ 1979 លោកបានទទួលចំណេះដឹង និងបទពិសោធន៍យ៉ាងទូលំទូលាយខាងផ្នែកសេវាហិរញ្ញវត្ថុ។ លោកបានទទួលបន្ទុកលើផ្នែកប្រតិបត្តិការនៅតាមសាខាមួយចំនួនដែលផ្តោតលើការលក់ផលិតផលឥណទាន។ លោកក៏បានទទួលបន្ទុកលើផ្នែកកម្ចីឯកជន និងកម្ចីសាជីវកម្ម ព្រមទាំងបម្រើការងារជា Corporate Loan Underwriter អស់រយៈពេល 8ឆ្នាំ។ បន្ទាប់មកលោកបានបម្រើការងារជាអ្នកគ្រប់គ្រងទូទៅនៅតាមបណ្តាសាខាជាច្រើនអស់រយៈពេល 5 ឆ្នាំ, លោកត្រូវបានតំឡើងតំណែងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ដែលទទួលខុសត្រូវលើការគ្រប់គ្រងកម្ចីឯកជន និងកម្ចីសាជីវកម្មរយៈពេល 2 ឆ្នាំ។

មុនចូលបម្រើការងារនៅ ដាប់ប៊ែលយូប៊ី ហ្វាយនែន លោកបានបម្រើការងារនៅធនាគារ អ៊ូរី ទីក្រុង សេអ៊ូល ជាអគ្គនាយករងប្រតិបត្តិ។ លោកក៏ធ្លាប់បម្រើការងារជានាយកគ្រប់គ្រងនៃផ្នែកកំណែទម្រង់អាជីវកម្មផងដែរ។

នៅខែធ្នូ ឆ្នាំ 2015 លោកបានទទួលតំណែងថ្មីជានាយកប្រតិបត្តិកំណែទម្រង់អាជីវកម្ម ព្រមទាំងបានធ្វើកំណែទម្រង់មួយចំនួន និងសេចក្តីសម្រេច M&A សម្រាប់ក្រុមហ៊ុនធំៗជាច្រើន។ ចាប់ពីឆ្នាំ 2016 ដល់ខែធ្នូ ឆ្នាំ2018 លោកបានទទួលតំណែងជាអគ្គនាយករងផ្នែកឥណទាន។

លោកបានទទួលបរិញ្ញាបត្រពាណិជ្ជកម្មដែលចេញពី សកលវិទ្យាល័យ Sejong។ ហើយលោកក៏បានទទួលវិញ្ញាបនបត្រសមត្ថភាពបញ្ជាក់ពី Fund Investment Advisor ជាបុគ្គលិកឥណទាន និងអ្នកវិភាគឥណទាន។

លោក គីម ឆាងយ៉ុន
អគ្គនាយកហិរញ្ញវត្ថុ

លោក គីម ឆាងយ៉ុន បានចូលបម្រើការងារនៅ ដាប់ប៊ែលយូប៊ី ហ្វាយនែន នៅក្នុងខែ មិថុនា ឆ្នាំ 2018 ជាមួយនឹងបទពិសោធន៍ដ៏ទូលំទូលាយជាង 32 ឆ្នាំ លើផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ និងប្រតិបត្តិការ នៅក្នុងសេវាធនាគារពាណិជ្ជកម្ម វិនិយោគទុន រតនាគារ និងសេវាពាណិជ្ជកម្មអន្តរជាតិ។

មុនចូលបម្រើការងារនៅ ដាប់ប៊ែលយូប៊ី ហ្វាយនែន លោកធ្លាប់បានបម្រើការងារជាមួយធនាគារ អ៊ូរី ទីក្រុងសេអ៊ូល ក្នុងមុខតំណែងជាប្រធានមជ្ឈមណ្ឌលសេវាពាណិជ្ជកម្មអន្តរជាតិ។ លោកក៏បានបម្រើការងារជាប្រធានគ្រប់គ្រងទូទៅនៃនាយកដ្ឋានរតនាគារផងដែរ។

លោកមានបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មពីសកលវិទ្យាល័យ Sogang ក្នុងទីក្រុងសេអ៊ូល។ លោកក៏ទទួលបានងារជាអ្នកវិភាគហិរញ្ញវត្ថុពី វិទ្យាស្ថាន C.F.A នៅក្នុងឆ្នាំ2005 ផងដែរ។

លោកស្រី តុប សុក្រសម្ភារ
អគ្គនាយិកាប្រតិបត្តិការ

លោកស្រី តុប សុក្រសម្ភារ បានចូលរួមបម្រើការងារជាមួយគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន នៅឆ្នាំ2002 ក្នុងតួនាទីជានាយកហិរញ្ញវត្ថុ និង កិច្ចការរដ្ឋបាល។ លោកស្រីបានទទួលតំណែងជាអគ្គនាយិកាប្រតិបត្តិការក្នុងឆ្នាំ2008។ មុនពេលលោកស្រីបានចូលរួមជាមួយគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន លោកស្រីបានបម្រើការងារជាសវនករជាន់ខ្ពស់នៅក្រុមហ៊ុន Ernst & Young និង Price water house Coopers។ បច្ចុប្បន្ន លោកស្រីគឺជាសមាជិក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាផងដែរ។

លោកស្រីមានបទពិសោធន៍ជាង 20 ឆ្នាំលើផ្នែកហិរញ្ញវត្ថុ គណនេយ្យ ការគ្រប់គ្រងយុទ្ធសាស្ត្រ និង ផែនការធុរកិច្ច សវនកម្ម រដ្ឋបាល និងទំនាក់ទំនង។

លោកស្រីបានបញ្ចប់ការសិក្សាថ្នាក់បិរញ្ញាបត្រ និង ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅប្រទេសកម្ពុជា។ លោកស្រីក៏បានទទួលវិញ្ញាបនបត្រថ្នាក់ជំនាញបច្ចេកទេសជាន់ខ្ពស់ផ្នែកគណនេយ្យ និង រដ្ឋបាលពីមហាវិទ្យាល័យ Noisy Le Grand នៃប្រទេសបារាំងផងដែរ។

លោក ព្រាប ពិសិដ្ឋ
នាយកប្រតិបត្តិការ

លោក ពិសិដ្ឋ មានស្រុកកំណើតនៅខេត្តកណ្តាល។ លោកមានបទពិសោធជាងមួយទសវត្សរ៍ លើវិស័យអភិវឌ្ឍន៍ សេវាបម្រើអតិថិជន គ្រប់គ្រងការឧបត្ថម្ភ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង និងទំនាក់ទំនងសាធារណៈនិងរដ្ឋបាល។ លោកបានចាប់ផ្តើមអាជីព ជាមួយ ដាប់ប៊ែលយូប៊ី ហ្វាយនែន នាឆ្នាំ2008។ មុនពេលចូលបម្រើការជាមួយ ដាប់ប៊ែលយូប៊ី ហ្វាយនែន លោកធ្លាប់បានបម្រើការងារជាមួយអង្គការទស្សនៈពិភពលោកអន្តរជាតិ (កម្ពុជា) និងលេខាធិការដ្ឋានមុខងារសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។

លោក ពិសិដ្ឋ ទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យ Global FTMS Campus នៅប្រទេសសិង្ហបូរី។ លោក ក៏ទទួលបានបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ក្នុងការគ្រប់គ្រងសហគ្រាស និងបរិញ្ញាបត្ររងផ្នែកវិជ្ជាជីវៈច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាផងដែរ។

លោក អ៊ាត ប៊ុន រ៉េត
នាយកហិរញ្ញវត្ថុ

លោក ប៊ុន រ៉េត បានបម្រើការងារជាមួយដាប់ប៊ែលយូប៊ី ហ្វាយនែន តាំងពីឆ្នាំ2008 ជាប្រធានសវនកម្ម បន្ទាប់មកជាប្រធានហិរញ្ញវត្ថុនិងរដ្ឋបាលក្នុងឆ្នាំ2015។ លោកបាននិងកំពុងបម្រើការងារក្នុងតួនាទីជានាយកហិរញ្ញវត្ថុចាប់ពីឆ្នាំ2018។

លោកមានបទពិសោធន៍ជាង 10 ឆ្នាំ លើផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ រតនាគារ ការរៀបចំផែនការអាជីវកម្ម រដ្ឋបាល ការត្រួតពិនិត្យផ្ទៃក្នុងនិងសវនកម្ម ពន្ធ ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ។ មុនពេលចូលបម្រើការងារនៅ ដាប់ប៊ែលយូប៊ី ហ្វាយនែន លោកធ្លាប់បម្រើការងារជាសវនករនៅអង្គការក្រៅរដ្ឋាភិបាល និង ក្រុមហ៊ុនអន្តរជាតិអស់រយៈពេល 5 ឆ្នាំ។

លោកទទួលបានបរិញ្ញាបត្រគ្រប់គ្រងអាជីវកម្មផ្នែកគណនេយ្យ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ លោកបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលទាំងក្នុងស្រុក និងអន្តរជាតិជាច្រើនដែលទាក់ទងនឹង គណនេយ្យនិងហិរញ្ញវត្ថុ មីក្រូហិរញ្ញវត្ថុ ការគ្រប់គ្រងសន្ទនីយភាព ការគ្រប់គ្រងហានិភ័យអាជីវកម្ម ការពិគ្រោះយោបល់ ការគ្រប់គ្រងផ្ទៃក្នុង និងស៊ើបអង្កេតការកែបន្លំ ពីប្រទេសសិង្ហបុរី ប្រទេសអ៊ីតាលី ប្រទេសឥណ្ឌូណេស៊ី ប្រទេសហ្វីលីពីន ប្រទេសអ៊ុយហ្គង់ដា និង ប្រទេសវៀតណាម។

លោក ឆាយ បញ្ញា
នាយកធនធានមនុស្ស

លោក បញ្ញា បានចាប់ផ្តើមអាជីពការងារជាមួយ ដាប់ប៊ែលយូប៊ី ហ្វាយនែន ក្នុងឆ្នាំ 2004 មានតួនាទីជា មន្ត្រីឥណទាន ហើយក៏បានផ្លាស់ប្តូរទៅជាប្រធានសាខា និងមុខតំណែងផ្សេងៗទៀតនៅក្នុងស្ថាប័ន។ លោកបានដឹកនាំនាយកដ្ឋានធនធានមនុស្សចាប់តាំងពីឆ្នាំ 2009 មក។

លោក បញ្ញា មានស្រុកកំណើតនៅខេត្តកំពង់ធំ ហើយលោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ2009។ លោក បញ្ញា បានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលទាំងក្នុងស្រុក និងអន្តរជាតិជាច្រើនដែលទាក់ទងនឹងការគ្រប់គ្រងធនធានមនុស្ស អាជីវកម្ម និងភាពជាអ្នកដឹកនាំអន្តរជាតិ នៅទីក្រុងបាងកក ទីក្រុងតូក្យូ ទីក្រុងឡុងដ៍ ប្រទេសអ៊ីតាលី ប្រទេសសិង្ហបុរី និងប្រទេសតង់ហ្សានី (អាហ្វ្រិក)។

លោក វ៉ា លួងសុរិន
នាយកព័ត៌មានវិទ្យា

លោក វ៉ា លួងសុរិន, បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យាពីសាកលវិទ្យាល័យ KMUT នៃទីក្រុងបាងកក ប្រទេសថៃ ក្នុងឆ្នាំ2009។ ជាមួយនឹងបទពិសោធន៍ជាង15 ឆ្នាំ លោក សុរិន បានអភិវឌ្ឍខ្លួនពីអ្នកបង្កើតកម្មវិធី អ្នកវិភាគប្រព័ន្ធព័ត៌មានវិទ្យា អ្នកគ្រប់គ្រងគម្រោងបច្ចេកវិទ្យាទៅកាន់ក្រុមហ៊ុនពហុជាតិ ជាច្រើនលើវិស័យផ្សេងៗដូចជា ការអភិវឌ្ឍកម្មវិធី ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណេត និងទូរគមនាគមន៍ ប្រឹក្សាយោបល់ផ្នែកព័ត៌មានវិទ្យា និងបច្ចុប្បន្ន លោកកំពុងដឹកនាំ និងគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា នៃគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែន។ មុនពេលចូលរួមជាមួយគ្រឹះស្ថាន ដាប់ប៊ែលយូប៊ី ហ្វាយនែនលោកបានបម្រើការងារនៅក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍អន្តរជាតិដ៏ល្បីល្បាញមួយ ជាអ្នកដឹកនាំក្រុមក្នុងការបង្កើត និងអនុវត្តន៍ green field project នៃ IT Core Billing System ព្រមទាំងគម្រោងទាក់ទងនឹងបច្ចេកវិទ្យាផ្សេងៗ ជួយទ្រទ្រង់ផ្នែកទីផ្សារនិងផ្សព្វផ្សាយពាណិជ្ជកម្មដើម្បីដាក់ចេញនូវផលិតផល និងសេវាថ្មីៗទៅលើទីផ្សារ ដែលធ្វើឲ្យរូបលោកត្រូវបានគេទទួលស្គាល់ និងទទួលបានរង្វាន់ជាអ្នកដឹកនាំ ក្នុងកម្មវិធីប្រចាំឆ្នាំសម្រាប់សមិទ្ធផល និងកិច្ចសហការល្អ។ លោក សុរិន បានចូលរួម និងទទួលបានការហ្វឹកហ្វឺនជាច្រើនលើវគ្គសិក្សាបច្ចេកទេស និងមិនមែនបច្ចេកទេស ទាំងក្នុង និងក្រៅប្រទេសដូចជា ប្រព័ន្ធទូទាត់ ប្រព័ន្ធវាយតម្លៃ និងគណនាតម្លៃ ការគ្រប់គ្រងហានិភ័យ ប្រព័ន្ធគ្រប់គ្រងគុណភាព ISO ស្តង់ដា 9001:2000 leadership blueprint ការគ្រប់គ្រងបន្តធុរកិច្ច សន្តិសុខប្រព័ន្ធព័ត៌មានវិទ្យា និងសវនកម្មផ្នែកព័ត៌មានវិទ្យា ITIL, បច្ចេកទេសប្រព័ន្ធ T24. លោក សុរិន ក៏ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីធ្វើបទបង្ហាញនៅតាមសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជាផងដែរ។

WB FINANCE
Save and Get Prizes!
3%
KOREAN DESK
KOREAN DESK
WB FINANCE
WB FINANCE
WB FINANCE

ចំណុចសំខាន់ៗ អំពីអាជីវកម្ម



ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗ

ទិន្នន័យសំខាន់ៗ

	ធ្នូ 2019	ធ្នូ 2018
ចំនួនអ្នកខ្ចីសកម្ម	133,284	137,017
ភាគរយ អ្នកខ្ចីជាស្ត្រី	83%	88%
ភាគរយ អ្នកខ្ចីតាមជនបទ	79%	79%
ភាគរយ អ្នកខ្ចីផ្នែកកសិកម្ម	48.55%	56.75%
ចំនួនតំបន់ប្រតិបត្តិការ	15	15
ចំនួនស្រុកប្រតិបត្តិការ	193	190
ចំនួនបុគ្គលិកសរុប	1,682	1,429
ផលប័ត្រឥណទាន	**$335,527,505**	**$218,256,087**
ផលប័ត្រឥណទាន ជាមធ្យមសម្រាប់អ្នកខ្ចីម្នាក់	$2,517	$1,593
ផលប័ត្រឥណទាន ជាមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់	$407,194	$317,694
ផលប័ត្រឥណទាន មានហានិភ័យ > 30 ថ្ងៃ	0.30%	0.64%
ប្រាក់បញ្ញើរបស់អតិថិជន	$66,268,862	$61,788,828
ចំនួនអ្នកដាក់ប្រាក់បញ្ញើ	193,458	117,478
សរុបទ្រព្យសកម្ម	**$379,942,841**	**$242,888,849**
មូលធនសរុប	**$82,842,901**	**$40,004,193**
ប្រាក់ចំណេញធៀបមូលធន	20.90%	11.10%
ប្រាក់ចំណេញធៀបទ្រព្យសកម្ម	4.12%	1.90%

វិធីសាស្ត្រប្រាក់កម្ចីតាមរយៈ ចំនួនអតិថិជន



វិធីសាស្ត្រប្រាក់កម្ចីតាមរយៈ ទំហំផលប័ត្រឥណទាន



គិតត្រឹមខែធ្នូ ឆ្នាំ 2019

ផលប័ត្រឥណទាន
US$ 336
គិតជាលានដុល្លារអាមេរិក

ចំនួនអតិថិជនកម្ចី
133,284

ចំនួនអតិថិជនបញ្ញើសន្សំពី
193,458

សមតុល្យប្រាក់បញ្ញើ-សន្សំ
US$ 66
គិតជាលានដុល្លារអាមេរិក

សរុបទ្រព្យសកម្ម
US$ 380
គិតជាលានដុល្លារអាមេរិក

និន្នាការកំណើន

សំពៀត ឥណទាន

ពីខែធ្នូឆ្នាំ 2015 ដល់ខែធ្នូឆ្នាំ 2019
(គិតជាលានដុល្លារអាមេរិក)



អតិថិជនកម្ចីសកម្ម

ពីខែធ្នូឆ្នាំ 2015 ដល់ខែធ្នូឆ្នាំ 2019



អតិថិជនបញ្ញើ-សន្សំ

ពីខែធ្នូឆ្នាំ 2015 ដល់ខែធ្នូឆ្នាំ 2019



សមតុល្យប្រាក់បញ្ញើ-សន្សំ

ពីខែធ្នូឆ្នាំ 2015 ដល់ខែធ្នូឆ្នាំ 2019

(គិតជាលានដុល្លារអាមេរិក)



ចំនួនទ្រព្យសកម្ម

ពីខែធ្នូឆ្នាំ 2015 ដល់ខែធ្នូឆ្នាំ 2019

(គិតជាលានដុល្លារអាមេរិក)



របាយការណ៍បង់ពន្ធ

ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានតម្លាភាពមួយយើងខ្ញុំសូមធ្វើការផ្សព្វផ្សាយជូនលោកអ្នកនូវរបាយការណ៍ពន្ធដែលបានបង់ ដូចមានបង្ហាញជូននៅក្នុងតារាងខាងក្រោម៖

គិតជាដុល្លារអាមេរិក	2015	2016	2017	2018	2019
ពន្ធប៉ាតង់	$7,210	$18,500	$18,500	$18,500	$18,500
ពន្ធតែមសារពើពន្ធលើផ្ទាំងផ្សាយពាណិជ្ជកម្ម	$16,446	$47,391	$70,042	$81,755	$64,790
កម្រៃអាជ្ញាប័ណ្ណបង់ជូនធនាគារជាតិក្នុងមួយសាខា	$285,188	$324,033	$319,774	$305,125	$297,500
ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ	$4,179	$4,041	$3,670	$1,788	$2,278
អាករលើតម្លៃបន្ថែម	$0	$691	$2,777	$2,325	$2,266
ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ	$306,781	$404,178	$390,145	$391,678	$500,668
ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	$807,394	$739,049	$1,113,913	$728,045	$3,457,620
ពន្ធលើប្រាក់បៀវត្ស	$427,216	$640,287	$464,239	$937,310	$696,947
ពន្ធកាត់ទុកលើនិវាសជន គណនីសន្សំមានកាលកំណត់	$71,671	$117,103	$149,201	$194,655	$204,791
ពន្ធកាត់ទុកលើនិវាសជន គណនីសន្សំគ្មានកាលកំណត់	$3,519	$7,280	$8,360	$10,384	$13,954
ពន្ធកាត់ទុកលើនិវាសជន ថ្លៃឈ្នួល	$100,295	$158,997	$183,169	$204,772	$252,800
ពន្ធកាត់ទុកលើនិវាសជន សេវាកម្មនានា សួយសារ	$216,860	$219,099	$124,042	$56,964	$82,451
ពន្ធកាត់ទុកលើអនិវាសជនការទូទាត់ថ្លៃសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា	$243,835	$231,987	$181,208	$275,755	$170,383
ពន្ធកាត់ទុកលើអនិវាសជន ការប្រាក់	$979,668	$1,195,994	$1,100,021	$895,329	$1,084,350
ពន្ធកាត់ទុកលើការបែងចែកភាគលាភ	$0	$0	$0	$1,384,017	$0
សរុប	**$3,470,262**	**$4,108,630**	**$4,129,061**	**$5,488,402**	**$6,849,297**
សរុបបង្គរទុក *	$12,103,247	$16,211,877	$20,340,938	$25,829,340	$32,678,637

“ ដាប់ប៊ែលយូប៊ី ហ្វាយនែន មានកិត្តិយសទទួលបាន វិញ្ញាបនបត្រ អនុលោមភាពសារពើពន្ធ កម្រិតមាស លើការប្រកាសពន្ធទាន់ពេលវេលា និង ការអនុវត្តល្អ តាមកាតព្វកិច្ចពន្ធ ពីអគ្គនាយកដ្ឋានពន្ធដារ។ ”

ការអភិវឌ្ឍធនធានមនុស្ស

"យកទេពកោសល្យជាអាទិភាព" គឺជាគុណតម្លៃស្នូលមួយរបស់ ដាប់ប៊ែលយូប៊ី ហ្វាយនែន។

យើងតែងតែយកចិត្តទុកដាក់ខ្ពស់លើការជ្រើសរើសបុគ្គលិក ការអភិវឌ្ឍសមត្ថភាព និងការរក្សាទុកនូវបុគ្គលិកដែលមានទេពកោសល្យ។

គិតត្រឹមបំណាច់ខែធ្នូ ឆ្នាំ 2019 នេះ ដាប់ប៊ែលយូប៊ី ហ្វាយនែន មានបុគ្គលិកសរុបចំនួន

1,682 នាក់

បុគ្គលិកស្ត្រីចំនួន 462 នាក់

តួលេខនេះបង្ហាញពីកំណើនចំនួន 253 នាក់បើប្រៀបធៀបកាលពីឆ្នាំ2018 កន្លងទៅ។

ការបណ្តុះបណ្តាលចំនួន **297** វគ្គ

មានសិក្ខាកាមចូលរួមសរុបប្រមាណ

18,600 នាក់

ចូលរួមវគ្គបណ្តុះបណ្តាលផ្តល់ដោយស្ថាប័នខាងក្រៅ និងវគ្គបណ្តុះបណ្តាលផ្តល់ជូនតាមប្រព័ន្ធអនឡាញ។

ទេពកោសល្យជាអាទិភាពរបស់យើង។ យើងបានធ្វើការវិនិយោគជាច្រើនលើការកសាងសមត្ថភាពបុគ្គលិក ដើម្បីបំពាក់នូវចំណេះដឹងនិងជំនាញថ្មីៗដល់ពួកគាត់។ គិតត្រឹមបំណាច់ខែធ្នូ ឆ្នាំ2019 នេះផងដែរ យើងបានផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកចំនួន 297 វគ្គ ដោយមានសិក្ខាកាមចូលរួមសរុបប្រមាណ 18,600 នាក់។ ចំនួននេះគិតទាំងវគ្គបណ្តុះបណ្តាលដែលរៀបចំដោយស្ថាប័នផ្ទាល់ វគ្គបណ្តុះបណ្តាលផ្តល់ដោយស្ថាប័នខាងក្រៅ និងវគ្គបណ្តុះបណ្តាលផ្តល់ជូនតាមប្រព័ន្ធអនឡាញ (E-Learning)។ ដោយក្រុមហ៊ុនយកចិត្តទុកដាក់ និងទទួលស្គាល់លើស្នាដៃការងារ និងការខិតខំប្រឹងប្រែងរបស់បុគ្គលិក យើងបានបញ្ជូនបុគ្គលិកចំនួន 22 នាក់ទៅទស្សនៈកិច្ចនៅការិយាល័យកណ្តាល ក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង។ ក្រៅពីនោះយើងក៏បានបញ្ជូនបុគ្គលិកចំនួន 8 នាក់ទៅចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសផ្សេងៗទៀតជាច្រើនផងដែរដូចជា ប្រទេសវៀតណាម ប្រទេសរុស្ស៊ី និងប្រទេសម៉ូរីស ជាដើម។

ដោយមើលឃើញពីតម្រូវការចាំបាច់ ដាប់ប៊ែលយូប៊ី ហ្វាយនែន នឹងធ្វើការវិនិយោគបន្ថែមទៀតក្នុងឆ្នាំ2020 នេះដោយទិញប្រព័ន្ធបណ្តុះបណ្តាលតាមអនឡាញដែលមានភាពងាយស្រួលប្រើប្រាស់ និងមានប្រសិទ្ធភាពខ្ពស់ ក្នុងគោលបំណងផ្តល់ភាពងាយស្រួល និងអាចឲ្យបុគ្គលិក រៀនសូត្របានភ្លាមៗ និងតាមតម្រូវការរបស់ពួកគាត់។

ដាប់ប៊ែលយូប៊ី ហ្វាយនែន
WB FINANCE
Information Desk
We Believe

ព័ត៌មានសំខាន់ៗ

ព្រឹត្តិការណ៍ក្នុងសង្គម

ព្រឹត្តិការណ៍សប្បុរសធម៌របស់ ដាប់បែលយូប៊ី ហ្វាយនែន នៅសាលាបឋមសិក្សាប៊ូយ៉ុងស្ពានទំលាប់

នៅថ្ងៃទី 22 ខែកុម្ភៈ ឆ្នាំ2019 ដាប់បែលយូប៊ី ហ្វាយនែន បានរៀបចំព្រឹត្តិការណ៍សប្បុរសធម៌មួយ នៅសាលាបឋមសិក្សាប៊ូយ៉ុងស្ពានទំលាប់ ស្ថិតនៅក្នុងខេត្តកណ្តាល។ ដាប់បែលយូប៊ី ហ្វាយនែន បានបរិច្ចាគថវិកាចំនួន 4,000 ដុល្លារអាមេរិក សៀវភៅសម្រាប់អានដាក់ក្នុងបណ្ណាល័យ និង សម្ភារៈសិក្សាជាច្រើនផ្សេងទៀតដល់សិស្សានុសិស្សរាប់រយនាក់។

សកម្មភាពក្នុងសង្គមរបស់ដាប់បែលយូប៊ី ហ្វាយនែន ជាមួយធនាគារជាតិនៃកម្ពុជា

នៅថ្ងៃទី19 ខែសីហា ឆ្នាំ2019 ដាប់បែលយូប៊ី ហ្វាយនែន បានរួមសហការជាមួយធនាគារជាតិនៃកម្ពុជាក្នុងការរៀបចំសកម្មភាពសប្បុរសធម៌នៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត និងគ្លីនិកទន្តសាស្ត្រពុទ្ធិសាស្ត្រ។ ដាប់បែលយូប៊ី ហ្វាយនែន បានចូលរួមឧបត្ថម្ភជាទឹកបរិសុទ្ធនិងភេសជ្ជៈដែលគិតជាទឹកប្រាក់ស្មើនឹង 2,000 ដុល្លារអាមេរិក។

ការចូលរួមបរិច្ចាគឈាមរបស់បុគ្គលិក ដាប់ប៊ែលយូប៊ី ហ្វាយនែន

នៅថ្ងៃទី16 ខែធ្នូ ឆ្នាំ2019 ដាប់ប៊ែលយូប៊ី ហ្វាយនែន បានរៀបចំកម្មវិធីបរិច្ចាគឈាម ដើម្បីជួយគាំទ្រដល់ មជ្ឈមណ្ឌលជាតិផ្តល់ឈាមកម្ពុជា និងជាសកម្មភាពមនុស្សធម៌ជួយសង្គ្រោះជីវិតជនរងគ្រោះ។ នេះជាយុទ្ធនាការលើកទី 4 នៃកម្មវិធីបរិច្ចាគឈាមរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន ដែលបានរៀបចំនៅការិយាល័យកណ្តាល ដោយមានការចូលរួមស្ម័គ្រចិត្តបរិច្ចាគឈាមពីសំណាក់គណៈគ្រប់គ្រង និងបុគ្គលិកគ្រប់លំដាប់ថ្នាក់។

ការប្រារព្ធពិធីបុណ្យណូអែល

នៅថ្ងៃទី29 ខែធ្នូ ឆ្នាំ2019 ដាប់ប៊ែលយូប៊ី ហ្វាយនែន បានរៀបចំសកម្មភាពកំសាន្ត សម្រាប់ថ្ងៃបុណ្យណូអែលនិងលើកទឹកចិត្តឱ្យកុមារទាំងអស់ស្រលាញ់ការសិក្សាដើម្បីអនាគតភ្លឺស្វាង។ ដាប់ប៊ែលយូប៊ី ហ្វាយនែន ផ្តល់ជូននូវសៀវភៅ ប៊ិច ខ្មៅដៃ ទឹកដោះគោ នំប៉ុង ទឹក បបរ ប៉េងប៉ោង និងអាវយឺត ដល់កុមារចំនួន 478 នាក់នៅក្នុងខេត្តកំពង់ធំ។

មូលនិធិជួយសង្គ្រោះរបស់បុគ្គលិកដាប់ប៊ែលយូប៊ី ហ្វាយនែន

បានបង្កើតឡើងក្នុងគោលបំណងជួយដល់បុគ្គលិកតាមរយៈការបរិច្ចាគដោយបុគ្គលិកស្ម័គ្រចិត្តជារៀងរាល់ខែ។ មូលនិធិនេះត្រូវបានបង្កើតឡើងនាខែធ្នូ ឆ្នាំ2012 និងត្រូវបានប្រើដើម្បីផ្តល់ជាអំណោយដល់បុគ្គលិក និងក្រុមគ្រួសារ ក្នុងគ្រាលំបាកនានា។ ក្នុងឆ្នាំ2019 ដាប់ប៊ែលយូប៊ី ហ្វាយនែន បានចូលរួមវិភាគទាន "មូលនិធិជួយសង្គ្រោះរបស់បុគ្គលិកដាប់ប៊ែលយូប៊ី ហ្វាយនែន" ចំនួន 62 ករណីដែលប្រឈមនឹងបញ្ហា សរុបថវិកាចំនួន 60,000,000 រៀល សម្រាប់ចូលរួមក្នុងពិធីបុណ្យសព គ្រោះមហន្តរាយ និងការព្យាបាលផ្សេងៗ រួមទាំងកិច្ចការសង្គមជាច្រើនទៀតផងដែរ។

សកម្មភាពបុគ្គលិកដាប់ប៊ែលយូប៊ី ហ្វាយនែន

ដំណើរកម្សាន្តប្រចាំឆ្នាំ2019

កាលពីថ្ងៃទី17- 18 ខែសីហា ឆ្នាំ2019 នៅរមណីយដ្ឋានបឹងសរីទ្ធី ខេត្តកំពង់ធំ កន្លងទៅនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន បានរៀបចំដំណើរកម្សាន្តប្រចាំឆ្នាំ2019 សម្រាប់បុគ្គលិក ក្រោមពាក្យស្លោក គ្រួសារតែមួយ វាសនាតែមួយ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន រៀបចំដំណើរកម្សាន្ត សម្រាប់បុគ្គលិក ក្នុងគោលបំណងដើម្បីឲ្យបុគ្គលិកមានភាពសប្បាយរីករាយ ពង្រឹងសាមគ្គីភាពនិងស្មារតីក្រុម។ ក្នុងដំណើរកម្សាន្តប្រចាំឆ្នាំនេះ មានរយៈពេល1យប់ 2ថ្ងៃ សម្រាប់បុគ្គលិកទាំងអស់បានចូលរួមសកម្មភាពកម្សាន្តសប្បាយផ្សេងៗដូចជាការទទួលទានអាហារពេលល្ងាច ការច្រៀងរាំ លេងល្បែងកម្សាន្ត ហែលទឹក និងជិះកង់។ល។

ការប្រកួតបាល់ទាត់មិត្តភាព ដាប់ប៊ែលយូប៊ី ហ្វាយនែន

ដាប់ប៊ែលយូប៊ី ហ្វាយនែន បានរៀបចំការប្រកួតបាល់ទាត់ប្រចាំសប្តាហ៍ រវាងបុគ្គលិកនិងថ្នាក់ដឹកនាំមកពីគ្រប់សាខាទូទាំងប្រទេសកម្ពុជា។

រង្វាន់ និងការទទួលស្គាល់

ដាប់ប៊ែលយូប៊ី ហ្វាយនែន បានរៀបចំប្រជុំទៀងទាត់ ដើម្បីធ្វើការវាយតម្លៃការងារនិងពិនិត្យឡើងវិញនូវយុទ្ធសាស្ត្ររបស់ខ្លួនក្នុងគោលបំណង លើកកម្ពស់សេវាហិរញ្ញវត្ថុ ដើម្បីបម្រើអតិថិជនឱ្យកាន់តែប្រសើរឡើង។ ដើម្បីជាការលើកទឹកចិត្ត ការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តរបស់បុគ្គលិក ដាប់ប៊ែលយូប៊ី ហ្វាយនែន បានប្រគល់រង្វាន់ និងវិញ្ញាបនបត្រទទួលស្គាល់ជាច្រើនដល់បុគ្គលិក។

ដំណើរទស្សនកិច្ចរបស់បុគ្គលិកទៅកាន់ការិយាល័យកណ្តាលធនាគារ អ៊ូរី ក្នុងទីក្រុងសេអ៊ូល

ជាផ្នែកមួយនៃការផ្លាស់ប្តូរវប្បធម៌និងការចែករំលែកការអនុវត្តធនាគារល្អបំផុត បុគ្គលិក 10 នាក់មកពី ដាប់ប៊ែលយូប៊ី ហ្វាយនែន ត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងកម្មវិធីប្រចាំឆ្នាំ "កម្មវិធីគ្រួសារអ៊ូរីឆ្នាំ2019" នៅទីស្នាក់ការកណ្តាលរបស់ធនាគារអ៊ូរី ប្រទេសកូរ៉េខាងត្បូង។

ពិព័រណ៍

ដាប់ប៊ែលយូប៊ី ហ្វាយនែន បានចូលរួម ពិព័រណ៍កុមារនិង គ្រួសារ លើកទី7

ដាប់ប៊ែលយូប៊ី ហ្វាយនែន បានចូលរួម ពិព័រណ៍កុមារនិងពិព័រណ៍គ្រួសារលើកទី 7 នៅកោះពេជ្ររយៈពេល 2 ថ្ងៃ ដោយបានបង្ហាញដល់អ្នកចូលរួមរាប់ពាន់នាក់ដែលមានចំណាប់អារម្មណ៍លើសេវាកម្ម និងផលិតផលរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន ។

ដាប់ប៊ែលយូប៊ី ហ្វាយនែន បានចូលរួមមហោស្រពពិព័រណ៍វិទ្យាសាស្រ្តកម្ពុជា

នៅថ្ងៃទី28 -29 ខែវិច្ឆិកា ឆ្នាំ2019 ដាប់ប៊ែលយូប៊ី ហ្វាយនែន បានចូលរួមក្នុងឱកាសមហោស្រពពិព័រណ៍វិទ្យាសាស្រ្តកម្ពុជា ប្រចាំឆ្នាំលើកទី15 នៅមជ្ឈមណ្ឌលដីព្រៃមៀរសែន សុខ ដើម្បីចូលរួមលើកស្ទួយ ការអប់រំទាក់ទងនឹងជំនាញ STEM និងការការពារបរិស្ថានដែលប្រកបដោយនិរន្តរភាព។

ដាប់ប៊ែលយូប៊ី ហ្វាយនែន ចូលរួមក្នុង ពិព័រណ៍ការងារ និងផលិតភាពជាតិឆ្នាំ2019

នៅថ្ងៃទី02 -03 ខែវិច្ឆិកា ឆ្នាំ2019 ដាប់ប៊ែលយូប៊ី ហ្វាយនែន បានចូលរួមក្នុងពិព័រណ៍ការងារ និងផលិតភាពជាតិឆ្នាំ2019 ក្នុងគោលបំណងចែករំលែកឱកាសការងារដល់បេក្ខជន ក៏ដូចជានិស្សិតតាមសាកលវិទ្យាល័យនានា នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ ដែលបានរៀបចំឡើងដោយ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រោមកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ និងសមាគមរោងចក្រកាត់ដេរ នៅកម្ពុជា (GMAC)។

ដាប់ប៊ែលយូប៊ី ហ្វាយនែន
WB FINANCE
ដំណើរកម្សាន្តប្រចាំឆ្នាំ
Work Hard & Work Smart
RUNNING

អំពីភាពជោគជ័យរបស់អតិថិជន

លោក ម៉ៅ សុខួន

អ្នកម៉ៅការសំណង់

លោក ម៉ៅ សុខួន បានមានប្រសាសន៍ថា "កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន បានជួយឱ្យខ្ញុំមានលទ្ធភាពទទួលគម្រោងសំណង់បុរីបានកាន់តែច្រើន និងកាន់តែធំ ព្រមទាំងជួយបន្ថែមកម្លាំងពលកម្មពីចំនួនប្រមាណ 30 នាក់ រហូតដល់ 200 នាក់ ដើម្បីអាចឱ្យដំណើរការគម្រោងសាងសង់ប្រព្រឹត្តទៅដោយរលូន និងទាន់ពេលវេលា។"

លោក ក៏បានបញ្ជាក់ផងដែរថា "ខ្ញុំធ្លាប់ជាកម្មករសំណង់ស៊ីឈ្នួលឱ្យគេ និងរស់នៅក្នុងបន្ទប់ជួលទំហំ 16 ម៉ែត្រការ៉េ។ ប៉ុន្តែឥឡូវនេះ ខ្ញុំជាម្ចាស់ គម្រោងសាងសង់ ជាអ្នកបើកប្រាក់ឈ្នួលឱ្យគេ និងជាម្ចាស់បន្ទប់ជួលចំនួន 32 បន្ទប់ទៀតផង"។

លោក ម៉ៅ សុខួន មានអាយុ 36 ឆ្នាំបានចាប់កំណើតនៅក្នុងគ្រួសារកសិករមួយក្នុងខេត្តស្វាយរៀង។ លោកបានផ្លាស់មករស់នៅភ្នំពេញជាង 15ឆ្នាំហើយ ដែលកាលពីដើមឡើយបានបម្រើការងារជាកម្មករសំណង់។ ដោយសារតែ លោក មានទេពកោសល្យ និងមានឆន្ទៈចង់មានការងារជារបស់ខ្លួនឯង ជាមួយនឹងជំនាញដែលខ្លួនមាន លោក ក៏បានចាប់ផ្ដើមទទួលម៉ៅការគម្រោងសាងសង់ខ្នាតតូច និងមធ្យម។ លោក មានភរិយាឈ្មោះ តន សុខហៀង អាយុ 37 ឆ្នាំ និងមានកូនប្រុស 2 នាក់ ដែលម្នាក់មានអាយុ 11 ឆ្នាំ និងម្នាក់ទៀតមានអាយុ 8 ឆ្នាំ។ សព្វថ្ងៃ ពួកគេរស់នៅក្នុងសង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ។

លោក សុខួន ក៏បានបង្ហើបឱ្យដឹងផងដែរថា "មុនពេលប្រើប្រាស់កម្ចីពីដាប់ប៊ែលយូប៊ី ហ្វាយនែន ខ្ញុំអាចត្រឹមតែទទួលម៉ៅការគម្រោងសាងសង់តូចៗ ជាមួយកម្លាំងពលកម្មប្រមាណជា 30 នាក់ប៉ុណ្ណោះ ហើយខ្ញុំអាចរកប្រាក់ចំណូលបានប្រហែល 300 ទៅ 500 ដុល្លារអាមេរិកក្នុងមួយសប្ដាហ៍។ ប៉ុន្តែ បន្ទាប់ពីបានប្រើប្រាស់កម្ចីចំនួន 2 វគ្គមក ខ្ញុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលម៉ៅការគម្រោងសាងសង់របស់បុរីធំៗមួយចំនួន ដែលគម្រោងនីមួយៗមានផ្ទះចំនួនរាប់រយខ្នង។ បច្ចុប្បន្ន ខ្ញុំមានកម្លាំងពលកម្ម ចំនួនប្រមាណជា 200 នាក់ដែលកំពុងបម្រើការងារក្នុងគម្រោងសាងសង់បុរីផ្សេងៗគ្នា ហើយខ្ញុំអាចរកចំណូលបានប្រហែល 1,000 ដុល្លារអាមេរិកក្នុងមួយសប្ដាហ៍។"

លោកបានចាប់ផ្ដើមស្នើសុំកម្ចីលើកទី1 ចំនួន 20,000 ដុល្លារអាមេរិក ពីដាប់ប៊ែលយូប៊ី ហ្វាយនែន នាឆ្នាំ 2016 ដើម្បីទិញសម្ភារៈសំណង់ចាំបាច់មួយចំនួន។ ចាប់តាំងពីពេលនោះមក មុខរបរម៉ៅការសំណង់របស់លោក មានការរីកចម្រើនជាបន្តបន្ទាប់ ដោយបានទទួលគម្រោងថ្មីៗ និងត្រូវការកម្លាំងពលកម្មកាន់តែច្រើនផងដែរ។ ដោយ មើលឃើញពីតម្រូវការកើនឡើងនៃគម្រោងសាងសង់ លោកបានសម្រេចស្នើសុំកម្ចីលើកទី 2 ចំនួន 100,000 ដុល្លារអាមេរិកនាឆ្នាំ 2019 ដើម្បីទិញសម្ភារៈសំណង់ បន្ថែមទៀត។ ទន្ទឹមនឹងនោះ លោកក៏បានប្រើប្រាស់កម្ចីទី2 របស់លោកមួយចំនួនដើម្បីសាងសង់អគារ មានបន្ទប់ជួលចំនួន 32 បន្ទប់។ លោកនឹងត្រូវចំណាយប្រាក់ប្រមាណជា 120,000 ដុល្លារអាមេរិកលើការសាងសង់នេះ ប៉ុន្តែ លោកនឹងទទួលបានចំណូលមកវិញប្រមាណជា 1,120 ដុល្លារអាមេរិកក្នុងមួយខែពីការជួលបន្ទប់។

លោក សុខួន បង្ហាញពីសេចក្ដីពេញចិត្តយ៉ាងខ្លាំងចំពោះកម្ចីពីដាប់ប៊ែលយូប៊ី ហ្វាយនែន ដែលបានជួយឱ្យ លោក មានឱកាសបញ្ចេញសក្ដានុពល និងទេពកោសល្យរបស់លោក។ ជាពិសេស លោកបង្ហាញពីអារម្មណ៍រីករាយជាមួយនឹងជីវភាពរស់នៅ ក៏ដូចជាភាពរីកចម្រើនក្នុងគ្រួសារ។

អ្នកស្រី ស៊ឹម សុខឃីម

កសិករ

អ្នកស្រី ស៊ឹម សុខឃីម បានមានប្រសាសន៍ជាមួយនឹងមោទនភាពថា “ក្នុងគ្រាដែលគ្រួសាររបស់ខ្ញុំស្ថិតក្នុងភាពលំបាកនាឆ្នាំ 2008 មានគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើនបានបដិសេធសំណើសុំកម្ចីរបស់ខ្ញុំ។ ក៏ប៉ុន្តែ ខ្ញុំមានសង្ឃឹមឡើងវិញដោយសារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន បានផ្តល់ឱកាសឱ្យខ្ញុំ ដោយបានអនុម័តកម្ចីលើកដំបូងរបស់ខ្ញុំចំនួន 500,000 រៀល (ប្រមាណ 125 ដុល្លារអាមេរិក)។ បន្ទាប់មក ជាមួយកម្ចីវគ្គក្រោយៗទៀត ស្រាប់តែមានស្ថាប័នហិរញ្ញវត្ថុមួយចំនួនបានមកទាក់ទងខ្ញុំសម្រាប់ការផ្ទេរប្រាក់កម្ចី។ សម្រាប់ខ្ញុំវាគឺជារឿងដែលគួរឱ្យខ្មាស់អៀនទៅវិញទេ បើខ្ញុំធ្វើរឿងបែបនោះ។ ខ្ញុំអាចបញ្ជាក់ប្រាប់ថា កម្ចីលើកក្រោយទៀតក៏ជាមួយដាប់ប៊ែលយូប៊ី ហ្វាយនែន ដែរ។”

អ្នកស្រី មានអាយុ 46 ឆ្នាំ និងស្វាមីរបស់អ្នកស្រី លោក ឡុន ឈុនលី មានអាយុ 48 ឆ្នាំ។ លោកស្រី និងស្វាមី ព្រមទាំងកូនចំនួន 2 នាក់ រស់នៅភូមិអន្លង់ ឃុំស្ដៅ ស្រុកកងមាស ខេត្តកំពង់ចាម។ លោកស្រីក៏មានកូនស្រីម្នាក់កំពុងបម្រើការងារនៅប្រទេសកូរ៉េខាងត្បូង និងកូនប្រុសម្នាក់ទៀតកំពុងបម្រើការងារក្នុងរាជធានីភ្នំពេញ។ បន្ទាប់ពីបានប្រើប្រាស់កម្ចីជាក្រុមចំនួន 3 វគ្គមក អ្នកស្រីក៏បានសំរេចចិត្តស្នើសុំកម្ចីលើកទី4 ជាឥណទានឯកត្តបុគ្គលចំនួន 45,000 ដុល្លារអាមេរិកដើម្បីទិញត្រាក់ទ័រមួយគ្រឿងសម្រាប់ជួលធ្វើកសិកម្ម ហើយស្វាមីរបស់អ្នកស្រីបាននិងកំពុងប្រើប្រាស់វាដើម្បីជួលធ្វើកសិកម្មឱ្យអ្នកភូមិ ដោយទទួលបានប្រាក់ចំណូលខ្ពស់។

អ្នកស្រី ក៏បានបញ្ជាក់ផងដែរថា “មុនពេលប្រើប្រាស់កម្ចី គ្រួសាររបស់ខ្ញុំមានចំណូលមិនច្បាស់លាស់ពីការនេសាទបែបប្រពៃណីក្នុងទន្លេក្បែរផ្ទះប្រហែល 80,000 រៀល (ប្រមាណ 20 ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ។ ឥឡូវនេះ ជាមួយនឹងត្រាក់ទ័រនេះ ស្វាមីរបស់ខ្ញុំអាចរកចំណូលបានប្រហែល 500,000 រៀល (ប្រមាណ 125 ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ ពីព្រោះយើងអាចទទួលបានកម្រៃ 70,000 រៀល (ប្រមាណ 17.50 ដុល្លារអាមេរិក) ក្នុងមួយម៉ោងពី សេវាជួលត្រាក់ទ័រ។ ចំណែកខ្ញុំវិញដាំបន្លែ និងចិញ្ចឹមត្រីលក់ឱ្យអ្នកភូមិ។”

បន្ទាប់មក អ្នកស្រីបានស្នើសុំកម្ចីទី5 ចំនួន 17,000 ដុល្លារអាមេរិក ពីដាប់ប៊ែលយូប៊ី ហ្វាយនែន ដើម្បី សាងសង់ផ្ទះថ្មីកម្ពស់ 2 ជាន់ធ្វើពីបេតុងមានទំហំសរុប 180 ម៉ែត្រការ៉េ។ ផ្ទះថ្មីនេះខុសប្លែកឆ្ងាយពីផ្ទះចាស់របស់អ្នកស្រីដែលមានដំបូលប្រក់ស័ង្កសី និងមានទំហំត្រឹមតែ 30 ម៉ែត្រការ៉េ ប៉ុណ្ណោះ។

នាពេលអនាគត អ្នកស្រី និងស្វាមី គ្រោងនឹងស្នើសុំកម្ចីបន្ថែមដើម្បីទិញគ្រឿងចក្រជីកដីចំនួន 1 ឬ 2 គ្រឿងបន្ថែមទៀតពីព្រោះ អ្នកស្រី មើលឃើញពីឱកាសនៃការបង្កើនប្រាក់ចំណូលបានច្រើនពីអាជីវកម្មប្រភេទនេះនៅក្នុងតំបន់។

អ្នកស្រី សារុំ សោភ័ណ្ឌ

ម្ចាស់ហាងលក់ទូរសព្ទ និងជាងសម្អាង

អ្នកស្រី សារុំ សោភ័ណ្ឌ បានបង្ហាញនូវអារម្មណ៍ពិតជាមួយនឹងសេចក្តីរំភើបថា "កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន មិនត្រឹមតែជួយបង្កើនផលិតភាពអាជីវកម្មរបស់ខ្ញុំប៉ុណ្ណោះទេ ថែមទាំងជួយលើកកិត្តិយសក្រុមគ្រួសាររបស់ខ្ញុំទៀតផង។ ឥឡូវនេះ អ្នករស់នៅជិតខាងមើលមកខ្ញុំ ជាម្ចាស់អាជីវកម្មជោគជ័យម្នាក់។ ចំណែកខ្ញុំវិញក៏យល់ថាខ្លួនឯងទទួលបានជោគជ័យដែរ។"

អ្នកស្រី មានអាយុ 38 ឆ្នាំ និងស្វាមីរបស់អ្នកស្រី លោក រុន ឆាយលី អាយុ 31 ឆ្នាំ រស់នៅស្រុកមុខកំពូល ខេត្តកណ្តាល។ អ្នកស្រី មានកូនស្រីអាយុ 9 ឆ្នាំម្នាក់កំពុងរៀនថ្នាក់ទី 4 នៅសាលាបឋមសិក្សា។ លោកស្រី ត្រូវបានគេទទួលស្គាល់ថាជាម្ចាស់អាជីវកម្មជោគជ័យ តាមរយៈកម្ចីចំនួន 2 វគ្គពី ដាប់ប៊ែលយូប៊ី ហ្វាយនែន។

មុនពេលប្រើប្រាស់កម្ចីពីដាប់ប៊ែលយូប៊ី ហ្វាយនែន សម្ភារៈគ្រឿងសម្អាង និងទូរដាក់ទូរសព្ទរបស់ អ្នកស្រី នៅលាយលំគ្នាក្នុងផ្ទះចាស់ទំហំ 20 ម៉ែត្រការ៉េ ដែលមានដំបូលប្រក់ស័ង្កសី។ អាជីវកម្មរបស់អ្នកស្រីពិតជាពិបាលភ្នែកមើលណាស់។ ស្វាមីរបស់អ្នកស្រីអាចលក់ទូរសព្ទបានត្រឹមតែ 1 ឬ 2 គ្រឿងប៉ុណ្ណោះក្នុងមួយថ្ងៃ។

ដោយមើលឃើញពីបញ្ហានេះ អ្នកស្រី និងស្វាមីបានរិះគិតរកវិធីកែលម្អអាជីវកម្ម ក៏ដូចជាជម្រករបស់ពួកគេ។ គាប់ជួនពេលនោះ មានបុគ្គលិករបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន បានមកជួបនិងបានណែនាំអ្នកស្រី និងស្វាមីអំពី កម្ចីកែលម្អគេហដ្ឋាន និង កម្ចីអាជីវកម្ម តាមរយៈវិធីសាស្ត្រសងរំលោះមានភាពបត់បែន និងអត្រាការប្រាក់សមរម្យ។ ដោយមិនបង្អង់យូរ អ្នកស្រី ក៏បានស្នើសុំកម្ចី ទី1 ចំនួន 30,000 ដុល្លារអាមេរិកក្នុងឆ្នាំ 2019 ដើម្បីសាងសង់ផ្ទះថ្មី។ បន្ទាប់មក អ្នកស្រី បានស្នើសុំកម្ចីទី2 ចំនួន 9,000 ដុល្លារអាមេរិកក្នុងឆ្នាំ 2020 នេះ ដើម្បីទិញទូរសព្ទមកស្តុកឱ្យបានច្រើន និងដើម្បីផ្តល់ជម្រើសបង់រំលស់ដល់អតិថិជននៅពេលពួកគេទិញទូរស័ព្ទ។

អ្នកស្រី ក៏បានបង្ហើបឱ្យដឹងផងដែរថា "បច្ចុប្បន្ន ខ្ញុំមានផ្ទះធ្វើពីបេតុងទំហំ 65 ម៉ែត្រការ៉េ ចំណែកអាជីវកម្មរបស់ខ្ញុំវិញពិតជាទាក់ទាញភ្នែកអតិថិជនទាំងអស់ដែលធ្វើដំណើរឆ្លងកាត់ទៅមក។ ស្វាមីរបស់ខ្ញុំអាចលក់ទូរសព្ទបានចន្លោះពី 5 ទៅ 8 គ្រឿងក្នុងមួយថ្ងៃ ដែលជាការលក់លើសផែនការកំណត់របស់ក្រុមហ៊ុន (នៅពេលណាការលក់លើសផែនការកំណត់ ក្រុមហ៊ុនឱ្យជាប្រាក់រង្វាន់លើកទឹកចិត្តចំនួន 4 ដុល្លារអាមេរិកបន្ថែមទៀតក្នុងទូរសព្ទមួយគ្រឿង)។"

អ្នកស្រី ពិតមានអារម្មណ៍សប្បាយរីករាយឥតឧបមាជាមួយនឹងការរីកចម្រើននៃអាជីវកម្ម ហើយអ្នកស្រីបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ដាប់ប៊ែលយូប៊ី ហ្វាយនែន ដែលបានជួយលើកស្ទួយអាជីវកម្ម និងជីវភាពរស់នៅក្នុងក្រុមគ្រួសាររបស់អ្នកស្រី។

អ្នកស្រី សុខ ស្រីពៅ

ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ

អ្នកស្រី សុខ ស្រីពៅ បានបញ្ជាក់ប្រាប់ដោយភាពជឿជាក់ថា "ប្រាក់កម្ចីទី1 ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន បានជួយខ្ញុំចាប់ផ្តើមមុខរបរចិញ្ចឹមសត្វ ។ ប្រាក់កម្ចីទី2 បានជួយខ្ញុំជួសជុលផ្ទះឈើ រីឯប្រាក់កម្ចីទី3 បានជួយខ្ញុំបង្កើនចំនួនគោ និងមាន់នៅក្នុងកសិដ្ឋានរបស់ខ្ញុំ។ គ្រាន់តែគោពីរក្បាលប៉ុណ្ណោះ អាចឱ្យខ្ញុំរកប្រាក់ចំណូលបានពី 13 លានរៀល ដល់ 14 លានរៀល (ប្រមាណ 2,350-3,500 ដុល្លារអាមេរិក) ក្នុងមួយឆ្នាំ។ តើអ្នកអាចទាយបានទេថាខ្ញុំមានគោចំនួនប៉ុន្មានក្បាលឥឡូវនេះ ដោយមិនទាន់រាប់បញ្ចូលសត្វមាន់រាប់រយក្បាលផ្សេងទៀតរបស់ខ្ញុំ?"

ជាស្ត្រីដែលមានភាពឧស្សាហ៍ព្យាយាមម្នាក់ អ្នកស្រី សុខ ស្រីពៅ មានអាយុ 36 ឆ្នាំរស់នៅភូមិដំណាក់អំពិល ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល។ អ្នកស្រី មានស្វាមីឈ្មោះមឿន ម៉ុន អាយុ 36 ឆ្នាំ និងមានកូនស្រីម្នាក់អាយុ 11 ឆ្នាំ ដែលកំពុងសិក្សានៅថ្នាក់ទី6។

អ្នកស្រី ជាបុគ្គលិកបម្រើការងារនៅក្នុងមន្ទីរពិសោធន៍របស់ក្រុមហ៊ុនឱសថមួយកន្លែង ប៉ុន្តែអ្នកស្រី មានបំណងចង់ស្វែងរកប្រភពចំណូលបន្ថែមទៀត ដើម្បីឱ្យគ្រួសារមានជីវភាពប្រសើរជាងមុន។ ហេតុដូច្នេះហើយ អ្នកស្រី និងស្វាមី បានសម្រេចចិត្តស្នើសុំ កម្ចីលើកដំបូងជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន ដើម្បីចាប់ផ្តើមមុខរបរចិញ្ចឹមសត្វ គឺចិញ្ចឹមគោ និងមាន់សម្រាប់លក់ឱ្យទីផ្សារក្នុងស្រុក។ អ្នកស្រី បានចាប់ផ្តើមជាមួយនឹង កម្ចីដំបូងចំនួន 2,000 ដុល្លារអាមេរិក ពីដាប់ប៊ែលយូប៊ី ហ្វាយនែន ដើម្បីទិញគោចំនួន 3 ក្បាល និងមាន់មួយចំនួន។ ស្វាមីរបស់អ្នកស្រី ក៏បានលាឈប់ពីការងារជាកម្មកររោងចក្រហើយមកផ្តោតលើមុខរបរចិញ្ចឹមសត្វនេះវិញ។

អ្នកស្រី ក៏បានបន្តទៀតថា "កាលពីមុនប្រើប្រាស់កម្ចី ចំណូលគ្រួសាររបស់ខ្ញុំជាមធ្យមប្រហែល 30,000 រៀល (ប្រមាណ 7.50 ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ ប៉ុន្តែឥឡូវនេះ ប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ខ្ញុំយ៉ាងហោចណាស់ 60,000 រៀល (ប្រមាណ 15 ដុល្លារអាមេរិក) ហើយឥឡូវនេះយើងមានម៉ូតូ 3 គ្រឿងសម្រាប់សមាជិកគ្រួសារ។"

ដោយមើលឃើញថា កម្ចីដំបូងទទួលបានជោគជ័យ អ្នកស្រី ក៏បានស្នើសុំ កម្ចីទី2 ចំនួន 3,000 ដុល្លារអាមេរិក ដើម្បីកែលម្អគេហដ្ឋានរបស់អ្នកស្រី។ ជាលទ្ធផល អ្នកស្រី មានផ្ទះឈើសមរម្យមួយសម្រាប់ក្រុមគ្រួសារ។ បន្ទាប់មកនាឆ្នាំ 2019 អ្នកស្រី បានសម្រេចចិត្តស្នើសុំ កម្ចីទី3 ចំនួន 6,000 ដុល្លារអាមេរិក ដើម្បីបន្ថែមចំនួនទ្រុងសម្រាប់សត្វគោ និងមាន់របស់អ្នកស្រី។ បច្ចុប្បន្ន អ្នកស្រីមានគោចំនួន ១៣ ក្បាល និងមាន់រាប់រយក្បាល ដែល ជួយឱ្យគ្រួសាររបស់អ្នកស្រីទទួលបានប្រាក់ចំណូលល្អ និងមានជីវភាពធូរធារជាងមុនច្រើន។ ជាពិសេស អ្នកស្រី នៅតែបន្តបម្រើការងារ និងទទួលបានប្រាក់បៀវត្សពីក្រុមហ៊ុនឱសថជាធម្មតា។

អ្នកស្រី និងស្វាមី មានសេចក្តីត្រេកអរជាខ្លាំងចំពោះបំលាស់ប្តូរជីវភាពរស់នៅក្នុងគ្រួសារ។ អ្នកស្រីបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន ដែលបានផ្តល់ឱកាស និងបានត្រួសត្រាយផ្លូវឆ្ពោះទៅរកភាពជោគជ័យនេះ។

ផលិតផល
និងសេវាកម្មរបស់យើង

ប្រាក់កម្ចី
ប្រាក់សន្សំ
ផលិតផល
និងសេវាកម្មប្រកប
ដោយភាពច្នៃប្រឌិត
សេវាធនាគារចល័ត
សេវាផ្ទេរប្រាក់
ATM
សេវា និង ប័ណ្ណអេធីអឹម

ផលិតផល និងសេវាកម្មរបស់យើង

កម្ចីអាជីវកម្ម

កម្ចីអាជីវកម្ម គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ជាទុនបង្វិល ដើមទុនវិនិយោគសម្រាប់ អាជីវកម្ម ការទិញទ្រព្យអាជីវកម្ម ការជួញដូរអាជីវកម្ម រួមបញ្ចូលទាំង ការជួញដូរផ្នែកកសិកម្ម និងប្រើប្រាស់ផងដែរ សម្រាប់សកម្មភាពរកប្រាក់ចំណូលដែលទទួលផលចំណូលជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ជារៀងរាល់2សប្តាហ៍ ឬប្រចាំខែ។

រូបិយប័ណ្ណ	រៀល ដុល្លារ និង បាត
ទំហំកម្ចី	80,000 – 40,000,000 រៀល
	100 – 100,000 ដុល្លារ
	800 – 400,000 បាត
រយៈពេលកម្ចី	03 – 84 ខែ
អត្រាការប្រាក់ប្រចាំខែ	1.00% – 1.50%

កម្ចីកសិកម្ម

កម្ចីកសិកម្ម គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ការចំណាយលើវត្ថុធាតុដើម ទ្រព្យសកម្មនៃអាជីវកម្ម កសិកម្ម ឬសកម្មភាពរកប្រាក់ចំណូលទាំងឡាយដែលទទួលផលចំណូលតាមរដូវកាល ដូចជា ការដាំដំណាំ ការចិញ្ចឹមសត្វ ។ល។

រូបិយប័ណ្ណ	រៀល ដុល្លារ និង បាត
ទំហំកម្ចី	80,000 – 40,000,000 រៀល
	100 – 50,000 ដុល្លារ
	800 – 400,000 បាត
រយៈពេលកម្ចី	03 – 72 ខែ
អត្រាការប្រាក់ប្រចាំខែ	1.00% – 1.50%

កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន

កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន គឺជាកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ទិញសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ឬទ្រព្យសម្បត្តិគ្រួសារ ក៏ដូចជាផ្តល់ហិរញ្ញប្បទានសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ក្នុងគោលបំណងធ្វើឲ្យជីវភាពរស់នៅជាមូលដ្ឋានមានភាពល្អប្រសើរ។

រូបិយប័ណ្ណ	រៀល ដុល្លារ និង បាត
ទំហំកម្ចី	80,000 – 40,000,000 រៀល
	100 – 25,000 ដុល្លារ
	800 – 400,000 បាត
រយៈពេលកម្ចី	03 – 60 ខែ
អត្រាការប្រាក់ប្រចាំខែ	1.15% – 1.50%

កម្ចីគេហដ្ឋាន

កម្ចីគេហដ្ឋាន គឺជាប្រភេទកម្ចីដែលត្រូវបានប្រើប្រាស់សម្រាប់ទិញ/សាងសង់ផ្ទះថ្មី ឬ កែលម្អផ្ទះដែលមានស្រាប់ ពង្រីក និងជួសជុលផ្ទះដែលមានស្រាប់។ កម្ចីនេះ ក៏អាចប្រើប្រាស់សម្រាប់ការទិញដីដើម្បីសាងសង់ផ្ទះផងដែរ។

រូបិយប័ណ្ណ	រៀល ដុល្លារ និង បាត
ទំហំកម្ចី	400,000 – 40,000,000 រៀល
	100 – 25,000 ដុល្លារ
	4,000 – 400,000 បាត
រយៈពេលកម្ចី	03 – 60 ខែ
អត្រាការប្រាក់ប្រចាំខែ	1.15% – 1.50%

កម្ចីការសិក្សា

កម្ចីការសិក្សា គឺជាប្រាក់កម្ចីផលិតផលសង្គម ដែលត្រូវបានប្រើប្រាស់សម្រាប់ជាជំនួយផ្នែកហិរញ្ញវត្ថុដល់បុគ្គល ឬ ឪពុកម្តាយ/អាណាព្យាបាល ដែលមានបំណងចង់ឲ្យកូនបានរៀនសូត្រនូវកម្មវិធីសិក្សាអប់រំចំណេះដឹងទូទៅ ឬ សម្រាប់បន្តការអប់រំជាន់ខ្ពស់ ឬ សិក្សាជំនាញវិជ្ជាជីវៈសម្រាប់ប្រកបរបរចិញ្ចឹមជីវិត។

រូបិយប័ណ្ណ	រៀល និង ដុល្លារ
ទំហំកម្ចី	400,000 – 4,000,000 រៀល
	100 – 3,000 ដុល្លារ
រយៈពេលកម្ចី	កម្រិតសិក្សាអប់រំចំណេះដឹងទូទៅ៖ 03 – 12 ខែ
	កម្រិតបរិញ្ញាបត្ររង ៖ 03 – 48 ខែ
	កម្រិតបរិញ្ញាបត្រ ៖ 03 – 84 ខែ
	កម្រិតអនុបណ្ឌិត ៖ 03 – 48 ខែ
	វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ៖ 03 – 24 ខែ
អត្រាការប្រាក់ប្រចាំខែ	1.30% – 1.50%

កម្ចីគ្រាអាសន្ន

កម្ចីគ្រាអាសន្ន គឺជាប្រភេទកម្ចីផលិតផលសង្គម ដែលត្រូវបានប្រើប្រាស់ដើម្បីធានាបាននូវការឆ្លើយតបទាន់ពេលវេលា ទៅនឹងតម្រូវការហិរញ្ញវត្ថុរបស់អតិថិជននៅក្នុងពេលមានហេតុការណ៍បន្ទាន់ និង/ឬព្រឹត្តិការណ៍ដែលមិនអាចគិតទុកជាមុន ទាំងគ្រោះធម្មជាតិ ឬ គ្រោះថ្នាក់ផ្ទាល់ខ្លួន។

រូបិយប័ណ្ណ	រៀល ដុល្លារ និង បាត
ទំហំកម្ចី	80,000 – 2,400,000 រៀល
	100 – 600 ដុល្លារ
	800 – 24,000 បាត
រយៈពេលកម្ចី	03 – 09 ខែ
អត្រាការប្រាក់ប្រចាំខែ	1.50%


កម្ចីគេហដ្ឋាន
11.63%
កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន
17.38%
កម្ចីអាជីវកម្ម
21.76%
អតិថិជន
កម្ចីគ្រាអាសន្ន
0.00%
កម្ចីកសិកម្ម
49.15%
កម្ចីការសិក្សា
0.07%


កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន
8.33%
កម្ចីគេហដ្ឋាន
25.61%
ផលប័ត្រ
ឥណទាន
កម្ចីកសិកម្ម
31.11%
កម្ចីអាជីវកម្ម
34.93%
កម្ចីគ្រាអាសន្ន
0.00%
កម្ចីការសិក្សា
0.02%

ប្រាក់សន្សំ



គណនីចម្រើនទ្រព្យ

គណនីចម្រើនទ្រព្យ គឺជាប្រភេទគណនីសន្សំ ដែលទទួលបានអត្រាការប្រាក់ខ្ពស់ និងមានលក្ខណៈជាកិច្ចសន្យាដែលតម្រូវឲ្យរក្សាទុកនូវសមតុល្យគណនី ក្នុងរយៈពេលកំណត់ជាក់លាក់មួយរហូតដល់កាលបរិច្ឆេទកំណត់។

រូបិយប័ណ្ណ	រៀល, ដុល្លារ និង បាត
សមតុល្យអប្បបរមា	100,000 រៀល
	25 ដុល្លារ
	1,000 បាត
រយៈពេល	01 – 36 ខែ
អត្រាការប្រាក់ប្រចាំឆ្នាំ	4.00% - 8.50%

គណនីសង្ឃឹម

គណនីសង្ឃឹម គឺជាប្រភេទគណនីសន្សំស្ម័គ្រចិត្ត ដែលបង្កើតឡើងសម្រាប់សហគ្រិន បុគ្គលិកក្រុមហ៊ុន ស្ត្រីមេផ្ទះ ដែលមានបំណងដាក់ប្រាក់សន្សំរបស់ពួកគេ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយដែលគួរឲ្យជឿទុកចិត្ត និងមានសុវត្ថិភាពខ្ពស់។

រូបិយប័ណ្ណ	រៀល, ដុល្លារ និង បាត
សមតុល្យអប្បបរមា	20,000 រៀល
	5 ដុល្លារ
	200 បាត
រយៈពេល	មិនមានរយៈពេលកំណត់
អត្រាការប្រាក់ប្រចាំឆ្នាំ	3.00% - 4.00%

គណនីកូនល្អ

គណនីកូនល្អ គឺជាប្រភេទគណនីសន្សំស្ម័គ្រចិត្ត ដែលបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ឪពុកម្តាយ ឬសាច់ញាតិ ដែលមានបំណងសន្សំប្រាក់សម្រាប់កូនៗរបស់ពួកគេ ដែលមានអាយុក្រោម 18 ឆ្នាំ។

រូបិយប័ណ្ណ	រៀល និង ដុល្លារ
សមតុល្យអប្បបរមា	20,000 រៀល 5 ដុល្លារ
រយៈពេល	រហូតដល់កុមារមានអាយុ 18 ឆ្នាំ
អត្រាការប្រាក់ប្រចាំឆ្នាំ	8.50% សម្រាប់រូបិយប័ណ្ណរៀល 6.50% សម្រាប់រូបិយប័ណ្ណដុល្លារ

គណនីសន្សំតាមផែនការ

គណនីសន្សំតាមផែនការ គឺជាប្រភេទគណនីសន្សំមានលក្ខណៈជាកិច្ចសន្យា ដែលតម្រូវឲ្យមានការដាក់ប្រាក់ចូលក្នុងគណនីនូវចំនួនស្មើៗគ្នាជារៀងរាល់ខែ។ គណនីនេះ ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនឯកត្តជនដែលមានចំណូលទៀងទាត់ និងមានបំណងជ្រើសរើសវិធីសាស្ត្រសន្សំបង្គរសម្រាប់ការវិនិយោគ ឬតម្រូវការអនាគត ដូចជា វិនិយោគក្នុងអាជីវកម្ម ទិញសម្ភារៈ ឬ ផែនការចូលនិវត្តន៍ ជាដើម។

រូបិយប័ណ្ណ	រៀល និង ដុល្លារ
សមតុល្យអប្បបរមា	40,000 រៀល 10 ដុល្លារ
រយៈពេល	03 – 36 ខែ
អត្រាការប្រាក់ប្រចាំឆ្នាំ	4.50% - 7.50%


គណនីចម្រើនទ្រព្យ
7.2%
គណនីសន្សំតាមផែនការ
0.1%
អតិថិជន
គណនីកូនល្អ
8.8%
គណនីសង្សឹម
83.9%


គណនីសង្សឹម
18.2%
គណនីកូនល្អ
2.5%
សមតុល្យប្រាក់បញ្ញើសន្សំ
គណនីចម្រើនទ្រព្យ
79.2%
គណនីសន្សំតាមផែនការ
0.1%

“សេវាហិរញ្ញវត្ថុដែលធ្វើឲ្យជីវិត
កាន់តែប្រសើរ និងអាជីវកម្ម
កាន់តែរីកចម្រើន។”

សេវាផ្ទេរប្រាក់ក្នុងស្រុក

សេវាផ្ទេរប្រាក់អន្តរសាខា

សេវាផ្ទេរប្រាក់អន្តរសាខា គឺជាប្រភេទសេវាមួយប្រភេទ ដែលអនុញ្ញាតឲ្យអតិថិជនអាចផ្ញើ/ផ្ទេរ ឬទទួលប្រាក់ ជាមួយសាខាទាំងអស់របស់ដាប់ប៊ែលយូប៊ី ហ្វាយនែន នៅក្នុងតំបន់តែមួយ ឬផ្សេងគ្នា ទៅតាមគោលបំណងរបស់ពួកគេ។

ប្រភេទនៃប្រតិបត្តិការ	សាច់ប្រាក់ ទៅសាច់ប្រាក់ ឬ គណនី ទៅ សាច់ប្រាក់			សាច់ប្រាក់ ទៅ គណនី ឬ គណនី ទៅ គណនី		
រូបិយប័ណ្ណ	រៀល	ដុល្លារ	បាត	រៀល	ដុល្លារ	បាត
អត្រាតម្លៃសេវា	0.10%	0.10%	0.10%	0.08%	0.08%	0.08%
តម្លៃសេវាអប្បបរមា	4,000	1	40	3,000	1	40

សេវាផ្ទេរប្រាក់អន្តរធនាគារ

សេវាផ្ទេរប្រាក់អន្តរធនាគារ គឺជាសេវាផ្ទេរប្រាក់មួយប្រភេទដែលធ្វើប្រតិបត្តិការរវាងស្ថាប័នហិរញ្ញវត្ថុ (ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) ដើម្បីផ្តល់នូវភាពងាយស្រួល និងសេវាកម្មរហ័សទៅដល់អតិថិជន ក្នុងគោលបំណងផ្ទេរប្រាក់របស់ពួកគេទៅកាន់គណនីអ្នកទទួល។

ចំនួនទឹកប្រាក់ផ្ទេរ (ជាប្រាក់រៀល)	តម្លៃសេវា (ជាប្រាក់រៀល)
តិចជាង ឬស្មើ 4 លាន	4,000
ចាប់ពី 4 លាន ដល់ 20 លាន	8,000
ចាប់ពី 20 លាន ដល់ 40 លាន	12,000

សេវាផ្ទេរប្រាក់ពីប្រទេស កូរ៉េ

សេវាទទួលប្រាក់ផ្ទេរពីប្រទេសកូរ៉េ

សេវាទទួលប្រាក់ផ្ទេរពីប្រទេសកូរ៉េ មកកាន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន ប្រទេសកម្ពុជា គឺជាប្រត្តិបត្តិការផ្ទេរប្រាក់ឆ្លងប្រទេសដែលមានភាពងាយស្រួល សុវត្ថិភាព និងទំនុកចិត្តខ្ពស់។ដាប់ប៊ែលយូប៊ី ហ្វាយនែន ផ្ដល់សេវាផ្ទេរប្រាក់នេះ ក្នុងគោលបំណងដើម្បីសម្រួលដល់អតិថិជន ទាំងអស់ដែលមានតម្រូវការទូរទាត់ ថ្លៃទំនិញ ឬផ្ញើប្រាក់មកកាន់ក្រុមគ្រួសារ ឬសាច់ញាតិរបស់ខ្លួនក្នុងប្រទេសកម្ពុជា។

លក្ខណៈពិសេស	
រូបិយប័ណ្ណ	ដុល្លារអាមេរិកតែប៉ុណ្ណោះ
ការទទួលប្រាក់	តាមរយៈគណនី របស់អ្នកទទួល នៅ ដាប់ប៊ែលយូប៊ី ហ្វាយនែន
ព័ត៌មានតម្រូវ សម្រាប់អ្នកផ្ទេរប្រាក់	ឈ្មោះគណនី លេខគណនីអាសយដ្ឋាន និងទូរសព្ទរបស់អ្នកទទួល

ចំនួនទឹកប្រាក់ប្រតិបត្តិការ	កម្រៃសេវា
≤ 5,000 ដុល្លារអាមេរិក	5.00 ដុល្លារអាមេរិក
> 5,000 ដុល្លារអាមេរិក	0.1% នៃចំនួនទឹកប្រាក់ផ្ទេរ

សេវាកម្មហិរញ្ញវត្ថុឌីជីថល

សេវាធនាគារចល័ត

ដើម្បីផ្តល់ជូនអតិថិជននូវសេវាធនាគារឌីជីថល កម្មវិធីធនាគារចល័តរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន ត្រូវបានដាក់ជូនអតិថិជនដើម្បីចូលប្រើប្រាស់គណនីបានប្រកបដោយសុវត្ថិភាព រហ័ស និងងាយស្រួលជាមួយមុខងារជាក់ស្តែងជាច្រើន។ កម្មវិធីធនាគារចល័តរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន អាចស្វែងរកបានទាំងនៅក្នុង App Store និង Play Store ហើយអនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការដូចមានក្នុងតារាង។

មុខងារ	ប្រតិបត្តិការ
ផ្ទេរប្រាក់	ផ្ទេរប្រាក់រវាងគណនីដាប់ប៊ែលយូប៊ី ហ្វាយនែន និងគណនីនៅធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងទៀត
បង់វិក្កយបត្រ	បង់ប្រាក់កម្ចីដាប់ប៊ែលយូប៊ី ហ្វាយនែន បង់ថ្លៃចំណាយប្រើប្រាស់
បញ្ចូលទឹកប្រាក់ទូរសព្ទ	បញ្ចូលទឹកប្រាក់ក្នុងទូរសព្ទដៃដោយមិនមានលេខកូដ ឬមានលេខកូដ
ស្នើសុំកម្ចី	ដាក់ពាក្យស្នើសុំប្រាក់កម្ចីដែលលោកអ្នកត្រូវការ
ពិនិត្យគណនី	មើលសមតុល្យគណនី និងប្រវត្តិប្រតិបត្តិការ

ប្រតិបត្តិការផ្សេងៗជាច្រើនទៀត នឹងត្រូវបានបន្ថែមជាបន្តបន្ទាប់ក្នុងកម្មវិធីធនាគារចល័តរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន ដើម្បីផ្តល់សេវាហិរញ្ញវត្ថុឌីជីថលឱ្យល្អបំផុតដល់អតិថិជនរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន។

សេវា និង ប័ណ្ណអេធីអឹម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន បានត្រៀមខ្លួនរួចរាល់ ដើម្បីផ្ដល់ជូនសេវា អេធីអឹម ទៅកាន់អតិថិជនរបស់ខ្លួនជាមួយភាពងាយស្រួល ភាពបត់បែន និង មានសុវត្ថិភាពខ្ពស់ទូទាំងតំបន់ប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន ទទួលបានការអនុញ្ញាត និងបានភ្ជាប់ប្រព័ន្ធអេធីអឹមរបស់ខ្លួនជាមួយប្រព័ន្ធ Cambodia Share Switch (CSS) របស់ធនាគារជាតិនៃកម្ពុជាបានដោយជោគជ័យ។ ទាំងអស់នេះបានផ្ដល់ភាពងាយស្រួលដល់អតិថិជនរបស់ដាប់ប៊ែលយូប៊ី ហ្វាយនែន អាចធ្វើប្រតិបត្តិការរបស់ខ្លួន នៅលើម៉ាស៊ីនអេធីអឹម របស់ដាប់ប៊ែលយូប៊ី ហ្វាយនែន ឬ ម៉ាស៊ីនអេធីអឹម ឬ ម៉ាស៊ីន POS របស់សមាជិកប្រព័ន្ធ Cambodia Share Switch (CSS) ដទៃទៀត បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន ផ្ដល់ជូននិងគាំទ្រមុខងារផ្សេងៗសម្រាប់អតិថិជន ដែលអាចធ្វើប្រតិបត្តិការ ហិរញ្ញវត្ថុ និង ប្រតិបត្តិការមិនមែនហិរញ្ញវត្ថុ នៅលើម៉ាស៊ីនអេធីអឹមដាប់ប៊ែលយូប៊ី ហ្វាយនែន និង ម៉ាស៊ីនអេធីអឹម ឬ ម៉ាស៊ីនPOS របស់ធនាគារដែលជាសមាជិកប្រព័ន្ធ Cambodia Share Switch (CSS) ដូចខាងក្រោម៖

ម៉ាស៊ីន ATM	ម៉ាស៊ីន POS
• ដកប្រាក់ (រួមបញ្ចូលទាំង ការដកសាច់ប្រាក់រហ័ស)	• ការទិញទំនិញ
• ពិនិត្យសមតុល្យសាច់ប្រាក់	• ពិនិត្យសមតុល្យសាច់ប្រាក់
• របាយការណ៍សង្ខេប	• ដកប្រាក់
• ប្ដូរលេខសម្ងាត់	
• ផ្ទេរប្រាក់ទៅកាន់គណនីនៅដាប់ប៊ែលយូប៊ី ហ្វាយនែន	
• ផ្ទេរប្រាក់ទៅកាន់ស្ថាប័នផ្សេងៗ	

របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

ចំនួនមធ្យមនៃកម្មករនិយោជិត បម្រើការងារពេញម៉ោងក្នុងមួយឆ្នាំ។

	2019	2018	2017	2016	2015
សូចនាកររលើការអនុវត្តផ្នែកបរិស្ថាន					
សម្ភារៈ					
ក្រដាស ប្រើគិតជាគីឡូក្រាម /FTE (1)	21.27	19.80	23.83	33.64	39.99
ទម្រង់ប្រាក់កម្ចី ប្រើគិតជាគីឡូក្រាម /FTE	5.25	5.77	5.76	11.06	17.02
ក្រដាសប្រើប្រាស់ក្នុងការិយាល័យ ប្រើគិតជាគីឡូក្រាម /FTE	16.03	14.03	18.07	22.58	22.97
សំណល់					
សំណល់ក្រដាស គិតជាគីឡូក្រាម /FTE	**2.45**	**3.12**	**2.01**	**1.00**	**2.94**
ក្រដាសជូតមាត់ ប្រើគិតជាគីឡូក្រាម	2,304.51	2,360.23	1,490.98	1,451.86	1633.90
ក្រដាសជូតដៃ ប្រើគិតជាគីឡូក្រាម	938.35	809.20	673.20	32.15	952.75
ក្រដាសបង្គន់ ប្រើគិតជាគីឡូក្រាម	658.11	1,152.26	618.74	66.26	1420.79
ថាមពល					
ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង /FTE	**607.07**	**617.00**	**668.11**	**493.92**	**636.70**
ប្រេងសាំង ប្រើគិតជាលីត្រ /FTE	**259.51**	**222.81**	**394.81**	**248.90**	**214.76**
ប្រេងសាំងសម្រាប់ទោចក្រយានយន្តប្រើគិតជាលីត្រ	411,685.15	306,716.76	544,565.35	384,342.65	291,269.69
ប្រេងសាំងសម្រាប់រថយន្ត ប្រើគិតជាលីត្រ	1,717.28	1,648.71	2,248.30	1,207	1,305
ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE	**39.64**	**48.23**	**67.01**	**50.90**	**51.01**
ប្រេងម៉ាស៊ូតសម្រាប់ម៉ាស៊ីនភ្លើងប្រើគិតជាលីត្រ	5,820.91	2,294.04	3,784.92	4847.22	4273.47
ប្រេងម៉ាស៊ូតសម្រាប់រថយន្ត ប្រើគិតជាលីត្រ	57,327.37	64,451	89,026	74,005	65,226

	2019	2018	2017	2016	2015
ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE	**N/A**	**N/A**	**N/A**	**N/A**	**N/A**
ការបញ្ចេញចោលនូវឧស្ម័នកាបូនិក (សមមូល គិតជាពាន់គីឡូក្រាម)(2)					
ចរន្តអគ្គិសនី	531.88	469.66	508.93	420.79	477.07
ប្រេងសាំង	992.17	740.08	1,312.35	925.32	702.18
ប្រេងម៉ាស៊ូត	173.66	183.55	255.23	216.84	191.12
ទឹក					
ទឹក ប្រើគិតជាម៉ែត្រគូប /FTE	**12.90**	**14.25**	**24.03**	**24.63**	**22.94**
ទឹក ប្រើគិតជាម៉ែត្រគូប	20,163.30	19,413.06	32,463.44	37,660.03	3,0891.46
ទឹកបរិសុទ្ធ ប្រើគិតជាម៉ែត្រគូប	391.43	304.74	818.31	489.02	361.01
ការធ្វើដំណើរ					
ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE	427.17	545	757	531	560
ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE	9,791.05	9,223.70	9,913.52	10,205.45	8,712.75
សូចនាករលើការអនុវត្តផ្នែកសង្គម					
ការបម្រើការងារ					
ចំនួនបុគ្គលិក	1,682	1,429	1,389	1,489	1,420
ស្រី	462	445	466	554	513
ប្រុស	1,220	984	923	935	907
ចំនួនបុគ្គលិក (FTE)	**1,593**	**1,384**	**1,385**	**1,549**	**1,362**

បណ្តាញសាខា និងតំបន់ប្រតិបត្តិការ

គិតត្រឹម ខែមីនា ឆ្នាំ 2020

គិតត្រឹមខែមីនា ឆ្នាំ2020 ដាប់ប៊ែលយូប៊ី ហ្វាយនែន មានការិយាល័យ ប្រចាំតំបន់ចំនួន 17 ការិយាល័យសាខាស្រុកចំនួន 136 ទូទាំង 25 រាជធានី ខេត្ត-ក្រុង ដែលមាន 197 ស្រុក 1,711 ឃុំ និង 11,300 ភូមិ ទូទាំងប្រទេសកម្ពុជា។

17 ការិយាល័យ ប្រចាំតំបន់

136 ការិយាល័យសាខាស្រុក

25 ទូទាំងរាជធានី ខេត្ត-ក្រុង

197 ស្រុក

1,711 ឃុំ

11,300 ភូមិទូទាំងប្រទេសកម្ពុជា

17 សាខាក្នុង **រាជធានីភ្នំពេញ**


ODDOR MEANCHEY
PREAH VIHEAR
(TBAENG MEANCHEY)
RATTANAKIRI
(BANLUNG)
BANTEAY MEANCHEY
SEREY SOPHORN
SIEM REAP
STUNG TRENG
BATTAMBANG
PAILIN
KAMPONG THOM
PURSAT
KRATIE
MONDULKIRI
SAEN MONOUROM
KAMPONG CHHNANG
KAMPONG CHAM
TBONG KHMUM
KOH KONG
TUOL KOUK
KAMPONG SPEU
CHBAR MORN
HEAD OFFICE
KANDAL
(TA KHMAO)
PREY VENG
SVAY RIENG
TAKEO
DAUN KEO
KAMPOT
SIHANOUKVILLE
(KAMPONG SOM)

របាយការណ៍ ហិរញ្ញវត្ថុ

27,410
26,718
26,190
25,714

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម				
សាច់ប្រាក់ក្នុងដៃ	1,364,666	5,561,014	3,634,344	14,602,796
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	11,848,839	48,284,019	7,967,726	32,014,325
សមតុល្យនៅធនាគារផ្សេងៗ	21,809,492	88,873,680	6,294,105	25,289,714
ឥណទានផ្តល់ដល់អតិថិជន	333,737,738	1,359,981,282	216,567,194	870,166,985
មូលបត្រវិនិយោគ	15,353	62,563	15,353	61,688
ទ្រព្យសម្បត្តិ និងបរិក្ខារ	2,056,267	8,379,288	1,689,913	6,790,069
ទ្រព្យសកម្មអរូបី	1,728,260	7,042,660	1,039,609	4,177,150
សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម	4,949,550	20,169,416	4,279,971	17,196,923
ទ្រព្យសកម្មពន្ធពន្យារ	1,463,963	5,965,650	870,449	3,497,464
ទ្រព្យសកម្មផ្សេងៗ	968,713	3,947,506	530,185	2,130,282
ទ្រព្យសកម្មសរុប	**379,942,841**	**1,548,267,078**	**242,888,849**	**975,927,396**

	ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
បំណុល និងមូលធន				
បំណុល				
ប្រាក់បញ្ញើរបស់អតិថិជន	66,268,862	270,045,613	61,788,828	248,267,511
បំណុលពន្ធចរន្ត	3,442,078	14,026,468	760,508	3,055,721
ប្រាក់កម្ចី	5,859,415	23,877,116	21,336,290	85,729,213
ចំនួនទឹកប្រាក់ត្រូវសងទៅភាគីពាក់ព័ន្ធ	213,214,331	868,848,399	110,885,644	445,538,518
បំណុលភតិសន្យា	4,835,174	19,703,334	4,197,945	16,867,343
បំណុលផ្សេងៗ	3,480,080	14,181,326	3,915,441	15,732,242
បំណុលសរុប	**297,099,940**	**1,210,682,256**	**202,884,656**	**815,190,548**
មូលធន				
ដើមទុន	60,000,000	240,000,000	30,000,000	120,000,000
ទុនបម្រុងតាមបទប្បញ្ញត្តិ	2,157,785	8,792,974	1,352,546	5,434,530
ប្រាក់ចំណេញរក្សាទុក	20,685,116	83,521,934	8,651,647	34,762,318
លម្អៀងនៃការប្តូររូបិយប័ណ្ណ	-	5,269,914	-	540,000
មូលធនសរុប	**82,842,901**	**337,584,822**	**40,004,193**	**160,736,848**
បំណុល និងមូលធនសរុប	**379,942,841**	**1,548,267,078**	**242,888,849**	**975,927,396**

របាយការណ៍លទ្ធផលលម្អិត

គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019

	ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលការប្រាក់	48,954,717	198,364,513	37,554,454	151,907,766
ចំណាយការប្រាក់	(12,046,089)	(48,810,753)	(14,456,948)	(58,478,355)
ចំណូលពីការប្រាក់សុទ្ធ	**36,908,628**	**149,553,760**	**23,097,506**	**93,429,411**
ចំណូលកម្រៃជើងសារ	1,574,728	6,380,798	3,408,532	13,787,512
ចំណាយកម្រៃជើងសារ	-	-	(267,403)	(1,081,645)
ចំណូលសុទ្ធពីកម្រៃជើងសារ	**1,574,728**	**6,380,798**	**3,141,129**	**12,705,867**
ប្រាក់ចំណូលផ្សេងទៀត	1,009,047	4,088,658	1,308,617	5,293,356
ចំណាយបុគ្គលិក	(13,347,625)	(54,084,577)	(12,847,320)	(51,967,409)
ចំណាយរំលស់	(2,180,411)	(8,835,025)	(1,897,153)	(7,673,984)
ចំណាយប្រតិបត្តិការផ្សេងៗ	(6,677,566)	(27,057,497)	(5,736,547)	(23,204,333)
ការខាតបង់សុទ្ធលើឱនភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ	(1,170,944)	(4,744,665)	(1,735,337)	(7,019,438)
ប្រាក់ចំណេញមុនដកពន្ធ	**16,115,857**	**65,301,452**	**5,330,895**	**21,563,470**
ចំណាយពន្ធលើប្រាក់ចំណូល	(3,277,149)	(13,279,008)	(1,122,678)	(4,541,233)
ប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ	**12,838,708**	**52,022,444**	**4,208,217**	**17,022,237**
ចំណូលលម្អិតផ្សេងៗ				
លម្អៀងនៃការប្តូររូបិយប័ណ្ណ	-	4,729,914	-	(262,398)
លទ្ធផលលម្អិតសរុបក្នុងឆ្នាំ	**12,838,708**	**56,752,358**	**4,208,217**	**16,759,839**

របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន

គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019

	ដើមទុន	ទុនបម្រុងតាមបទប្បញ្ញត្តិ	ប្រាក់ចំណេញរក្សាទុក	លម្អៀងនៃការប្ដូររូបិយប័ណ្ណ	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី 01 ខែ មករា ឆ្នាំ 2018	21,686,425	1,190,507	12,919,044	802,398	35,795,976
ប្រាក់ចំណេញប្រចាំឆ្នាំ	-	-	4,208,217	-	4,208,217
លម្អៀងនៃការប្តូររូបិយប័ណ្ណ	-	-	-	(262,398)	-
លទ្ធផលលម្អិតសរុប	**-**	**-**	**4,208,217**	**(262,398)**	**4,208,217**
ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	162,039	(162,039)	-	-
ការផ្ទេរមូលធន	8,313,575	-	(8,313,575)	-	-
	8,313,575	**162,039**	**(8,475,614)**	**-**	**-**
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	**30,000,000**	**1,352,546**	**8,651,647**	**-**	**40,004,193**
សមមូលពាន់រៀល	**120,000,000**	**5,434,530**	**34,762,318**	**540,000**	**160,736,848**
នាថ្ងៃទី 01 ខែ មករា ឆ្នាំ 2019	30,000,000	1,352,546	8,651,647	540,000	40,004,193
ប្រាក់ចំណេញប្រចាំឆ្នាំ	-	-	12,838,708		12,838,708
លម្អៀងនៃការប្តូររូបិយប័ណ្ណ	-	-	-	4,729,914	-
លទ្ធផលលម្អិតសរុប	**-**	**-**	**12,838,708**	**4,729,914**	**12,838,708**
ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	805,239	(805,239)	-	-
ការបោះផ្សាយមូលធន	30,000,000	-	-	-	30,000,000
	30,000,000	**805,239**	**(805,239)**	**-**	**30,000,000**
នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019	**60,000,000**	**2,157,785**	**20,685,116**	**-**	**82,842,901**
សមមូលពាន់រៀល	**240,000,000**	**8,792,974**	**83,521,934**	**5,269,914**	**337,584,822**

របាយការណ៍លំហូរទឹកប្រាក់

គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2019

	ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ				
ប្រាក់ចំណេញមុនដកពន្ធ	16,115,857	65,301,452	5,330,895	21,563,470
និយ័តកម្ម៖				
ចំណាយរំលស់	2,180,411	8,835,025	1,897,153	7,673,984
ការខាតបង់សុទ្ធលើឱនភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ	1,170,944	4,744,665	1,735,337	7,019,438
ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ	8,319	33,709	23,074	93,334
លម្អៀងនៃការប្តូររូបិយប័ណ្ណ	30,706	124,421	537,435	2,173,925
ចំណូលការប្រាក់	(48,954,717)	(198,364,513)	(37,554,454)	(151,907,766)
ចំណាយការប្រាក់	12,046,089	48,810,753	14,456,948	58,478,355
	(17,402,391)	**(70,514,488)**	**(13,573,612)**	**(54,905,260)**
បម្រែបម្រួលនៃទុនចល័ត៖				
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	(3,898,021)	(15,794,781)	(1,831,217)	(7,407,273)
ឥណទានផ្តល់ដល់អតិថិជន	(118,330,295)	(479,474,355)	(50,970,987)	(206,177,642)
ទ្រព្យសកម្មផ្សេងៗ	190,846	773,308	617,860	2,499,244
ប្រាក់បញ្ញើសន្សំពីអតិថិជន	4,458,778	18,066,968	15,129,915	61,200,506
បំណុលផ្សេងៗ	(435,361)	(1,764,083)	685,204	2,771,650
សាច់ប្រាក់ក្នុងសកម្មភាពប្រតិបត្តិការ	**(135,416,444)**	**(548,707,431)**	**(49,942,837)**	**(202,018,775)**
ការប្រាក់ទទួលបាន	48,325,343	195,814,290	37,312,924	150,930,778
ការប្រាក់បានបង់	(11,663,767)	(47,261,584)	(13,942,317)	(56,396,672)

	ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019		ដំណាច់ឆ្នាំ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
បង់ពន្ធលើប្រាក់ចំណូល	(1,189,093)	(4,818,205)	(1,507,094)	(6,096,195)
សាច់ប្រាក់សុទ្ធប្រើក្នុង សកម្មភាពប្រតិបត្តិការ	**(99,943,961)**	**(404,972,930)**	**(28,079,324)**	**(113,580,864)**
លំហូរសាច់ប្រាក់ពីសកម្មភាព វិនិយោគ				
ការទិញទ្រព្យ និងបរិក្ខារ	(1,111,059)	(4,502,011)	(551,597)	(2,231,210)
ការទិញទ្រព្យសកម្មអរូបី	(867,519)	(3,515,187)	(387,698)	(1,568,238)
សាច់ប្រាក់ទទួលបានពីការ លក់ទ្រព្យ និងបរិក្ខារ	1,256	5,089	1,385	5,602
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាព វិនិយោគ	**(1,977,322)**	**(8,012,109)**	**(937,910)**	**(3,793,846)**
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន				
សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី	981,595	3,977,423	25,050,000	101,327,250
ការទូទាត់សងប្រាក់កម្ចី	(16,113,696)	(65,292,696)	(111,076,489)	(449,304,398)
សាច់ប្រាក់ត្រូវសងទៅភាគីពាក់ព័ន្ធ	102,000,000	413,304,000	110,000,000	444,950,000
ការទូទាត់សងទៅភាគីពាក់ព័ន្ធ	-	-	(499,462)	(2,020,324)
ការទូទាត់ភតិសន្យា	(1,714,095)	(6,945,513)	(1,307,710)	(5,289,687)
សាច់ប្រាក់ទទួលបានពីការបោះផ្សាយភាគហ៊ុនថ្មី	30,000,000	121,560,000	-	-
សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន	**115,153,804**	**466,603,214**	**22,166,339**	**89,662,841**
ការកើន/ (ថយចុះឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល	13,232,521	53,618,175	(6,850,895)	(27,711,869)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ	10,234,927	41,123,941	17,085,822	68,975,461
លម្អៀងនៃការប្តូររូបិយប័ណ្ណ	-	887,735	-	(139,651)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ	**23,467,448**	**95,629,851**	**10,234,927**	**41,123,941**

របាយការណ៍របស់សវនករឯករាជ្យ

Deloitte.

Deloitte (Cambodia) Co., Ltd.
Vattanac Capital Tower
Floor 8, Unit 8, #66
Preah Monivong Blvd
Sangkat Wat Phnom
Khan Duan Penh
Phnom Penh, Cambodia

Tel: +855 (0) 23 963 777
Fax: +855 (0) 23 963 778
www.deloitte.com/kh

របាយការណ៍របស់សវនករឯករាជ្យ
ជូនចំពោះ ភាគទុនិកនៃ ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក

មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយនែន (“ក្រុមហ៊ុន”) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 និងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ហើយនិងសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗដែលបានចែងនៅទំព័រទី 8 ដល់ 107។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយ បង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”)។

មូលដ្ឋានក្នុងការផ្តល់មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែក *“ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ”* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយអនុលោមទៅតាមការតម្រូវក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ព្រមទាំងបានបំពេញនូវការទទួលខុសត្រូវលើក្រមសីលធម៌ផ្សេងៗទៀតដោយអនុលោមទៅតាមការតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានរៀបចំឡើង ស្របតាមស្តង់ដារគណនេយ្យកម្ពុជានិងបទបញ្ញត្តិ និងគោលការណ៍ណែនាំទាក់ទងនឹងគណនេយ្យដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា និងត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀតដែលបានផ្តល់នូវមតិយោបល់សវនកម្មដែលមិនមានការកែតម្រូវលើរបាយការណ៍ហិរញ្ញវត្ថុ នាថ្ងៃទី 21 ខែ មីនាឆ្នាំ 2019។

Deloitte.

ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះព័ត៌មានផ្សេងទៀត។ ព័ត៌មានផ្សេងទៀតគឺជារបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដូចមានចែងក្នុងទំព័រទី 1 ដល់ទី 4 ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំឡើយ។

មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់លើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានធានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗនេះដែរ។

ទាក់ទិននឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងៗនេះ ហើយពិចារណា ថាតើព័ត៌មានទាំងនេះ មានភាពខុសគ្នាជាសារវន្តឬទេ ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងដែលទទួលបានក្នុងការធ្វើសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះ មានកំហុសឆ្គងជាសារវន្តឬទេ។ យោងតាមការងារដែលយើងខ្ញុំបានធ្វើ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្ត ចំពោះព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវឲ្យរាយការណ៍ពីភាពពិតជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលតម្រូវឲ្យរាយការណ៍នោះទេ។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារ CIFRSs និងទទួលខុសត្រូវដូចគ្នាផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលើនិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងការកត់ត្រាគណនេយ្យរបស់ក្រុមហ៊ុន លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងចង់រំលាយ ឬបញ្ឈប់ប្រតិបត្តិការរបស់ក្រុមហ៊ុន ឬក៏គ្មានជម្រើសជាក់ស្តែងណាមួយក្រៅពីអនុវត្តដូច្នេះ។

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យ លើដំណើរការនៃការរាយការណ៍ អំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាដែលសមហេតុផលគឺជាការធានាអះអាង កម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា ការងារសវនកម្មដែលប្រព្រឹត្តទៅ ដោយអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា តែងតែរកឃើញជានិច្ច នូវកំហុសឆ្គងជាសារវន្តដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬបញ្ចូលគ្នាជារួម) អាចមានឥទ្ធិពលទៅលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុដែល បណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំផ្សេងៗ ដោយបានបង្កើត និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្រប សម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការ

Deloitte.

បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាងហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គង ដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចោលដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬមិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និង ការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋាន ទៅលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងប្រព័ន្ធគណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋានថាតើមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្តទាក់ទងនឹងព្រឹត្តការណ៍ ឬកាលៈទេសៈទាំងឡាយណាដែលនាំឲ្យមានការសង្ស័យជាសារវន្ត ទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍សវនករ លើកំណត់សម្គាល់ពាក់ពន្ធ័នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើ កំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយ-ការណ៍របស់សវនករ។ តែទោះជាយ៉ាងនេះក្តី ព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគត ក៏អាចបង្កឲ្យក្រុមហ៊ុន មិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។
- វាយតម្លៃការបង្ហាញទូទៅ មាតិកា និងខ្លឹមសារ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

យើងខ្ញុំទាក់ទងជាមួយអ្នកទទួលបន្ទុកអភិបាលកិច្ចពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗ ដូចជាវិសាលភាព និងពេលវេលានៃការធ្វើសវនកម្ម និងការរកឃើញពីសវនកម្ម រួមទាំងកង្វះខាតសំខាន់ៗនៃការត្រួតពិនិត្យផ្ទៃក្នុងដែលបានរកឃើញនៅក្នុងកំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

តំណាងក្រុមហ៊ុន ឌីឡូយធ៍ (ខេមបូឌា) ខូ អិលធីឌី

ឌុយ គឹមលេង
Partner

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ៖ ថ្ងៃទី15 ខែ ឧសភា ឆ្នាំ 2020

យើងកសាងទំនុកចិត្ត
អ្នករីកចម្រើន
We Build Trust.
You Prosper.
WB FINANCE

Woori Bank

120 years

បណ្តាញអន្តរជាតិរបស់ធនាគារ អ៊ូរី

បណ្ដាញសាខា

747 បណ្ដាញប្រតិបត្តិការក្នុងស្រុក

451 បណ្ដាញប្រតិបត្តិការក្នុង 26 ប្រទេស

ឆ្នាំ

2019

គម្រប់ខួបទី

ANNIVERSARY 120th

គិតត្រឹមត្រីមាសទី 3 ឆ្នាំ 2019

ទ្រព្យសកម្មសរុប

US$34 ពាន់លានដុល្លារអាមេរិក

ផលប័ត្រឥណទានសរុប

US$185 ពាន់លានដុល្លារអាមេរិក

ប្រាក់ចំណេញ

US$1.0 ពាន់លានដុល្លារអាមេរិក

របាយការណ៍នេះអាចទាញយកបានតាមរយៈ:
វេបសាយ៖ www.wbfinance.com.kh
អ៊ីម៉ែល៖ info@wbfinance.com.kh
លេខទូរស័ព្ទ៖ (855) 23 963 333
អគារលេខ ៣៩៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ